# ច្បាប់

# ស្តីពី

# ការត្រួតពិនិត្យគ្រឿងញៀន

# ព្រះរាជក្រម

នស/រកម/០១៩៧/០១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

*********

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើទី ៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១
## ការចាត់ថ្នាក់ថ្នាំញៀនឬសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងសារធាតុសម្រាប់ផលិតគ្រឿងញៀន

**មាត្រា ១.-**

ត្រូវចាត់ទុកជាគ្រឿងញៀន ថ្នាំញៀនទាំងឡាយ សារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទនិងគ្រឿងផ្សំទាំងឡាយ ដែលកំណត់ក្នុងតារាងខាងក្រោមនេះ :

តារាង I -រុក្ខជាតិនិងសារធាតុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយដែលគ្មានផលប្រយោជន៍អ្វីខាងវេជ្ជសាស្ត្រ ។

តារាង II -រុក្ខជាតិនិងសារធាតុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ។

តារាង III -រុក្ខជាតិ និងសារធាតុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ។

តារាង IV -សារធាតុនិងជាតិគីមីទាំងឡាយ ដែលប្រើប្រាស់សម្រាប់ផលិតគ្រឿងញៀននិងសម្រាប់ផលិតសារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ហើយដែលចាត់ថ្នាក់ក្នុងអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ១៩៨៨ ស្តីពីការប្រយុទ្ធប្រឆាំងនឹងជំនួញខុសច្បាប់នៃគ្រឿងញៀន និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬក្នុងការអនុវត្តអនុសញ្ញានេះប្រឆាំងនឹងការធ្វើជំនួញគ្រឿងញៀនខុសច្បាប់ ។

តារាងទាំង ៤ នេះ បានថែងជាលំអិតនៅក្នុងឧបសម្ព័ន្ធ ។

តារាងទាំងអស់នេះនឹងបានកែប្រែ ដោយប្រកាសរបស់ក្រសួងសុខាភិបាល ក្រោយពីបានសួរយោបល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ ពេលណាមានការចុះឈ្មោះគ្រឿងញៀនជាថ្មី ការលុបចេញឬការផ្ទេរពីតារាងមួយទៅតារាងមួយ ។

# ជំពូកទី ២
## ការហាមឃាត់ ការដាំរុក្ខជាតិញៀន ការផលិត ការប្រើប្រាស់ ការចែកចាយនិងការធ្វើជំនួញគ្រឿងញៀន

### មាត្រា ២.-

លើកលែងតែក្នុងករណីនៃមាត្រា១៤ ការដាំអាភៀន ដើមកូកា ដើមកញ្ឆា និងដើមកញ្ឆា ត្រូវហាមឃាត់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៣.-

លើកលែងតែក្នុងករណីនៃមាត្រា១៤ ត្រូវហាមឃាត់ការផលិត ការចែកចាយ និងការធ្វើជំនួញលក់ដុំឬលក់រាយ ការដឹកជញ្ជូន ការរក្សាទុក ការផ្តល់ឱ្យ ការចែកឱ្យដោយគិតថ្លៃឬឥតគិតថ្លៃ ការទិញ ការប្រើប្រាស់ ការនាំចេញ នាំចូលឬការឆ្លងកាត់និងការសិចតលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នូវរុក្ខជាតិ សារធាតុនិងគ្រឿងផ្សំដែលមានចែងក្នុងតារាង I ។

### មាត្រា ៤.-

ការផលិត ការធ្វើជំនួញនិងការចែកចាយដុំក្តី រាយក្តី ការធ្វើជំនួញអន្តរជាតិ ការប្រើប្រាស់រុក្ខជាតិ សារធាតុ និងការរៀបចំផ្សំធ្វើ ដែលបានចែងក្នុងតារាង II និង III ត្រូវបានហាមឃាត់ចំពោះជនណាក៏ដោយ ដែលគ្មានអាជ្ញាប័ណ្ណពិសេសពីរដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងចំពោះគ្រឹះស្ថានឬទីស្ថានណាមួយ ដែលឥតមានអាជ្ញាប័ណ្ណពិសេស ចេញឱ្យក្នុងល័ក្ខខ័ណ្ឌដូចគ្នា ។

បែបបទសម្រាប់អនុវត្តទាំងឡាយនៃមាត្រានេះ ហើយជាអាទិ៍បណ្តាបែបបទទាក់ទងទៅនឹងល័ក្ខខ័ណ្ឌនៃពាក្យសុំ និងសេចក្តីអនុញ្ញាត ទាក់ទងទៅនឹងមាតិកានិងការកំរិត ការផ្អាកមិនឱ្យប្រើនិងការលុបចោលនៃអាជ្ញាប័ណ្ណទាំងពីរ ត្រូវបានកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៥.-

ត្រូវហាមឃាត់ដូចគ្នានឹងខាងលើនេះដែរ ចំពោះរុក្ខជាតិ សារធាតុនិងគ្រឿងផ្សំដែលមានចែងក្នុងតារាង II និង III ជាពិសេសការឆ្លងកាត់និងការសិចតលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីរុក្ខជាតិ សារធាតុ ឬគ្រឿងផ្សំនោះដាក់ចុះឬមិនដាក់ចុះពីមធ្យោបាយដឹកជញ្ជូនក៏ដោយ លើក លែងតែការទិញ ការដឹកជញ្ជូន និងការរក្សាទុកសម្រាប់ផលិតឱសថព្យាបាលមនុស្ស ឬសត្វដែល ត្រូវស្ថិតនៅក្រោមការអនុញ្ញាតិ និងការត្រួតពិនិត្យនៃក្រសួងសុខាភិបាល ។

## មាត្រា ៦.-

វិធានការត្រួតពិនិត្យនិងតាមដាន ដែលមានចែងក្នុងច្បាប់នេះ ក៏ត្រូវប្រព្រឹត្តទៅនៅកំពង់ផែរួចពន្ធនិងនៅតំបន់រួចពន្ធដែរ ។

## មាត្រា ៧.-

រដ្ឋមន្ត្រីក្រសួងសុខាភិបាលកំណត់ ១ឆ្នាំម្តង នូវបរិមាណជាអតិបរមានៃរុក្ខជាតិ សារធាតុនិងគ្រឿងផ្សំផ្សេងៗ ដែលសហគ្រាសរដ្ឋនិងសហគ្រាសឯកជនត្រូវការដើម្បីផលិតឱសថព្យាបាលមនុស្ស ឬសត្វ តាមសេចក្តីត្រូវការជាក់ស្តែង ។

## មាត្រា ៨.-

ក្រសួងសុខាភិបាលនាំចូលរុក្ខជាតិ សារធាតុនិងគ្រឿងផ្សំផ្សេងៗ ដែលត្រូវការប្រចាំឆ្នាំសម្រាប់សហគ្រាសរដ្ឋឬសហគ្រាសឯកជនខាងលើនេះយកទៅផលិតឱសថ ។

សហគ្រាសឯកជនដែលផលិតឱសថព្យាបាលមនុស្ស ឬសត្វ ដែលត្រូវការទិញរុក្ខជាតិ សារធាតុឬគ្រឿងផ្សំដែលមានចែងក្នុងតារាង II និង III ត្រូវសុំទិញពីក្រសួងសុខាភិបាល ។

## មាត្រា ៩.-

ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីរុក្ខជាតិ សារធាតុ និងគ្រឿងផ្សំឬឱសថដែលមានចែងក្នុងតារាង II និង III ត្រូវហាមឃាត់ ។ ការផ្តល់គំរូ ឬរូបមន្តឱសថទៅឱ្យឯកជន ការផ្តល់គំរូ រុក្ខជាតិ

សារធាតុ ឬគ្រឿងផ្សំ ដែលមានចែងក្នុងតារាង II និង III ត្រូវហាមឃាត់ ។

## មាត្រា ១០.-

រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចចេញប្រកាសណែនាំបន្ថែមចំពោះការផ្សព្វផ្សាយពាណិជ្ជ-កម្ម ដែលមានចែងក្នុងមាត្រា ៩ ។

វិធានទាក់ទងនឹងការចេញអាជ្ញាប័ណ្ណនិងល័ក្ខខ័ណ្ឌ ដែលសហគ្រាសឬឯកជនណាម្នាក់អាចធ្វើសកម្មភាពចែងក្នុងច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១១.-

ការធ្វើ ការលក់ ទិញឬការចែកចាយដុំនិងការធ្វើពាណិជ្ជកម្មអន្តរជាតិនៃសារធាតុ ដែលមានចែងនៅក្នុងតារាង IV ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ៥ ដល់ ៨ នៃច្បាប់នេះ ។

## មាត្រា ១២.-

អ្នកផលិត អ្នកលក់ដុំនិងអ្នកលក់រាយ ដែលអនុញ្ញាតិដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវតែចុះក្នុងសៀវភៅបញ្ជីដែលមានបង់លេខទំព័រ និងចុះហត្ថលេខាសង្ខេបរបស់អាជ្ញាធរមានសមត្ថកិច្ចនូវរាល់ការទិញឬលក់សារធាតុ ដែលមានចែងក្នុងតារាង II, III និងIV ។

ការចុះបញ្ជីនេះ ត្រូវធ្វើនៅពេលប្រតិបត្តិការ ដោយឥតទុកចន្លោះ ឥតកោសលុប និងឥតសរសេរត្រួត ។

ការចុះបញ្ជីនេះត្រូវសរសេរបញ្ជាក់ ថ្ងៃ ខែ ឆ្នាំនៃប្រតិបត្តិការ ឈ្មោះ និងចំនួននៃផលិតផលដែលទទួលបាន ឬលក់ចេញ នាម អាសយដ្ឋាននិងមុខរបររបស់អ្នកទទួលទិញឬអ្នកលក់ ។

សៀវភៅបញ្ជីត្រូវរក្សាទុកក្នុងរយៈពេលដប់ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជីចុងក្រោយ ដើម្បីបង្ហាញទៅអាជ្ញាធរមានសមត្ថកិច្ចតាមសេចក្តីបង្គាប់ ។

**មាត្រា ១៣.-**

កាលបើមានសញ្ញាធ្ងន់ធ្ងរល្មមឱ្យសង្ស័យថា សារធាតុណាមួយក្នុងតារាង IV ជាសារធាតុសម្រាប់យកទៅផលិតថ្នាំញៀនដោយខុសច្បាប់ណាមួយ ឬសារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ សារធាតុនោះត្រូវឃាត់ទុកភ្លាម រង់ចាំលទ្ធផលនៃការស៊ើបអង្កេតរបស់តុលាការ។

## ជំពូកទី ៣

## ការស្រាវជ្រាវខាងវេជ្ជសាស្ត្រ ខាងវិទ្យាសាស្ត្រនិងខាងការសិក្សា

**មាត្រា ១៤.-**

ដើម្បីគោលដៅនៃការស្រាវជ្រាវខាងវេជ្ជសាស្ត្រ ខាងវិទ្យាសាស្ត្រ ខាងការសិក្សា ឬខាងនគរបាលវិទ្យាសាស្ត្រ រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចអនុញ្ញាតិអោយបុគ្គលនៃអង្គការរដ្ឋណាមួយ ផលិត ធ្វើ ទិញ ប្រើប្រាស់ រក្សាទុករុក្ខជាតិ សារធាតុនិងគ្រឿងផ្សំ ដែលមានចែងក្នុងតារាង I, II និង III ក្នុងបរិមាណមិនលើសពីចំនួនត្រូវការចាំបាច់ដាច់ខាត ។

អ្នកទទួលការអនុញ្ញាតិត្រូវចុះក្នុងសៀវភៅនូវបរិមាណនៃរុក្ខជាតិ សារធាតុគ្រឿងផ្សំ ដែលខ្លួនទិញ ធ្វើ ប្រើប្រាស់ និងកំទេចចោល ។ បញ្ជីនេះសាម៉ីខ្លួនត្រូវរក្សាទុក ១០ឆ្នាំ យ៉ាងតិច ។

ម្យ៉ាងទៀត ត្រូវចុះបញ្ជី ថ្ងៃ ខែ ឆ្នាំនៃប្រតិបត្តិការនិងឈ្មោះអ្នកផ្តល់ ។ រៀងរាល់ឆ្នាំ អ្នកទទួលការអនុញ្ញាតិ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាលអំពីបរិមាណប្រើប្រាស់ ឬកំទេចចោលនិងបរិមាណដែលមាននៅក្នុងសន្និធិ ។

## ជំពូកទី ៤

## អធិការកិច្ចនិងការពិនិត្យកត់ត្រាបទល្មើស

**មាត្រា ១៥.-**

គ្រប់បុគ្គល សហគ្រាសឯកជន សហគ្រាសរដ្ឋ គ្រឹះស្ថានវេជ្ជសាស្ត្រ គ្រឹះស្ថានឱសថសាស្ត្រ និងគ្រឹះស្ថានវិទ្យាសាស្ត្រ ដែលធ្វើសកម្មភាព ឬប្រតិបត្តិការណាមួយអំពីរុក្ខជាតិ សារធាតុគ្រឿងផ្សំ ឬឱសថដែលមានចែងក្នុងច្បាប់នេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការឃ្លាំ

មើលរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលត្រូវចាត់អធិការឱសថសាស្ត្រ ឱ្យធ្វើអធិការកិច្ចសាមញ្ញយ៉ាងតិចមួយឆ្នាំម្តង និងធ្វើអធិការកិច្ចវិសាមញ្ញគ្រប់ពេលវេលាលើគ្រឹះស្ថាន ទីស្ថានសន្និធិ និងលើការកត់ត្រាចុះបញ្ជី ។ អធិការក្រសួងសុខាភិបាល អាចសុំកំលាំងជំនួយចាំបាច់ ដើម្បីធ្វើអធិការកិច្ច ។

ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការឃ្លាំមើលខាងលើនេះដែរបន្ទប់ដែលតម្កល់ប្រអប់ដាក់ថ្នាំសម្រាប់សង្គ្រោះមធ្យោបាយដឹកជញ្ជូនសាធារណៈដែលឱ្យធ្វើការដឹកជញ្ជូនអន្តរជាតិ ។

បែបបទសម្រាប់អនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

### មាត្រា ១៦.-

ដោយពុំទាន់គិតដល់ការចោទប្រកាន់អំពីការដាំរុក្ខជាតិញៀន ការផលិត ការធ្វើឬការជួញគ្រឿងញៀនខុសច្បាប់ ប្រសិនបើមាន ត្រូវពិន័យជាប្រាក់ពី ១០០.០០០៛០០ (មួយសែនរៀល) ដល់១.០០០.០០០៛០០(មួយលានរៀល) ជនណាប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃសកម្មភាពត្រឹមត្រូវណាមួយ ដែលធ្វើឡើងក្នុងប្រយោជន៍វេជ្ជសាស្ត្រ ឬឱសថសាស្ត្រ បានល្មើសនឹងបទប្បញ្ញត្តិច្បាប់ និងបទបញ្ជាចំពោះ :

១-ការហាមឃាត់មិនអោយដាំរុក្ខជាតិញៀន ផលិតឬធ្វើជំនួញជុំឬរាយ ដឹកជញ្ជូន រក្សាទុកឱ្យលក់ចែកចាយ ប្រើប្រាស់ក្នុងរោងចក្រ នាំចូល នាំចេញ ដឹកជញ្ជូនដោយមានការសំចត នូវសារធាតុ ឬរុក្ខជាតិទាំងឡាយដែលបានចែងក្នុងតារាង I ។

២-អាជ្ញាប័ណ្ណអនុវត្តសកម្មភាពណាមួយដែលចែងខាងលើនេះ ឬល័ក្ខខ័ណ្ឌដែលបានតម្រូវដោយអាជ្ញាប័ណ្ណនេះ ។

៣-ការនាំចូលឬនាំចេញ ការដឹកជញ្ជូនដោយមានការសំចតលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានៃសារធាតុដែលចែងក្នុងតារាង II និង III ។

៤-ការកំរិតជាអតិបរមាដែលកំរិតដោយក្រសួងសុខាភិបាល ពីការផលិតសារធាតុ និងការរៀបចំផ្សំធ្វើ ដែលមានសារធាតុ ចែងក្នុងតារាង II និង III ។

៥-ការផ្សាយពាណិជ្ជកម្មអំពីផលិតផល ដែលមានសារធាតុចែងក្នុងតារាង II និងIII ។

៦-ការចែកចាយ ការចេញវេជ្ជបញ្ជា ការជាវថ្នាំផ្សំ ឬសារធាតុដែលចែងក្នុងតារាង II និង III ។

៧-ការចុះបញ្ជីនិងប្រតិបត្តិការនិងស្ថិតិ ដែលតម្រូវឱ្យធ្វើ ។

៨-ការផលិត ការធ្វើជំនួញ ឬការប្រើប្រាស់សារធាតុដែលចែងក្នុងតារាង I , II និង III សម្រាប់សកម្មភាពស្រាវជ្រាវខាងវេជ្ជសាស្ត្រ វិទ្យាសាស្ត្រ ឬការសិក្សា ។

ក្នុងករណីមិនរាងចាលត្រូវទ្វេរទោស ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ថ្ងៃ ដល់ ១ ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០៛០០ ( មួយលានរៀល) ដល់ ៥.០០០.០០០៛០០ ( ប្រាំលានរៀល ) ឬទោសណាមួយក្នុងទោសទាំងពីរនេះ ជនណាប្រឆាំងនឹងការបំពេញមុខងាររបស់អធិការឱសថសាស្ត្រ ទោះបីតាមមធ្យោបាយណាក៏ដោយ ។

## មាត្រា ១៧.-

ប្រសិនបើមានហេតុការណ៍ណាមួយបង្ហាញឱ្យឃើញថា ចារីនៃបទល្មើសទាំងឡាយ ដែលបានចែងក្នុងមាត្រា១៦ បានប្រព្រឹត្តសម្រាប់និយោជករបស់ខ្លួន និយោជកនេះត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ប្រាក់ពិន័យដែលសម្រេចដោយតុលាការ ។

# ជំពូកទី ៦
# ការបង្ការនិងរាវរកការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់

## ផ្នែកទី ១
## ការកំរិតចំនួននៃការទូទាត់ជាសាច់ប្រាក់

**មាត្រា ១៨.-**

ការទូទាត់ជាសាច់ប្រាក់ មានទឹកប្រាក់លើសពីចំនួនដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ត្រូវហាមឃាត់ ។

## ផ្នែកទី ២
## កាតព្វកិច្ចធ្វើប្រតិវេទន៍នៃការផ្ទេរជាអន្តរជាតិនៃរបស់មានតម្លៃ

**មាត្រា ១៩.-**

រាល់ការផ្ទេរទៅបរទេសឬមកពីបរទេសនូវមូនិធិ មូលប័ត្រ ឬរបស់មានតម្លៃផ្សេងៗ ដែលមានទឹកប្រាក់លើសពីចំនួនដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ត្រូវធ្វើប្រតិវេទន៍ទៅធនាគារជាតិនៃកម្ពុជា ។ ក្នុងប្រតិវេទន៍ ត្រូវប្រាប់ប្រភេទនិងចំនួនទឹកប្រាក់នៃការផ្ទេរ នាម និងអាសយដ្ឋានរបស់អ្នកផ្ទេរ និងអ្នកទទួល ។

## ផ្នែកទី ៣
## បទបញ្ញាអំពីមុខរបរជាអ្នកប្តូរប្រាក់ផ្ទាល់ដៃ

**មាត្រា ២០.-**

រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដែលបានទទួលការអនុញ្ញាតអោយប្រកបមុខរបរជាអ្នកប្តូរប្រាក់ផ្ទាល់ដៃត្រូវ :

១-ស្នើរបញ្ជាក់អំពីអត្តសញ្ញាណអតិថិជនរបស់ខ្លួន ដោយឱ្យគេបង្ហាញឯកសារជាភស្តុតាងដែលមានបិទរូបថត ហើយនៅមានសុពលភាពនៅឡើយមុននឹងប្តូរប្រាក់ដែលមានទឹកប្រាក់លើសពីចំនួនកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ។

២-កត់ត្រាប្រតិបត្តិការទាំងនោះ តាមលំដាប់កាលបរិច្ឆេទ ដោយបញ្ជាក់ពីគោត្តនាមនាមខ្លួន និងអាសយដ្ឋានរបស់អតិថិជន ក្នុងសៀវភៅបញ្ជីបង់លេខនិងចុះហត្ថលេខាសង្ខេបដោយធនាគារជាតិនៃកម្ពុជា ហើយរក្សាទុកបញ្ជីទាំងនេះរយៈពេល ៥ឆ្នាំ យ៉ាងតិច ក្រោយពីកិច្ចប្រតិ-បត្តិការចុងក្រោយដែលបានកត់ត្រា ។

ធនាគារជាតិនៃកម្ពុជាអាចចាត់មន្ត្រីរបស់ខ្លួន ឱ្យពិនិត្យមើលសៀវភៅបញ្ជីទាំងអស់នេះដល់ទីកន្លែង ។

៣-គោរពរាល់បទបញ្ជារបស់ធនាគារជាតិនៃកម្ពុជា ក្នុងសមត្ថកិច្ចគ្រប់គ្រងការប្តូរប្រាក់ ។

## ផ្នែកទី ៤
## ការចាត់ចែងកិច្ចការតម្រូវទៅលើគ្រឹះស្ថានល្បែង

**មាត្រា ២១.-**

កាលបើអ្នកលេងល្បែងទិញ ឬយកមកជាមួយ ឬដូរកាស ឬបួកសម្រាប់ស៊ីសងដែលមានតម្លៃលើសពីទឹកប្រាក់កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រឹះស្ថានល្បែងទាំងឡាយដែលមានការអនុញ្ញាតិពីរាជរដ្ឋាភិបាលត្រូវ :

១-ស្នើរបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកលេងល្បែង ដោយឱ្យគេបង្ហាញឯកសារជាភស្តុតាងដែលមានបិទរូបថត ហើយនៅមានសុពលភាពនៅឡើយ ។

២-ចុះបញ្ជីតាមលំដាប់កាលបរិច្ឆេទ នូវប្រតិបត្តិការទាំងនោះ តាមទឹកប្រាក់ជាក់ស្តែងបញ្ជាក់ពីគោត្តនាម នាមខ្លួននិងអាសយដ្ឋានរបស់អ្នកលេងល្បែង នៅក្នុងសៀវភៅបញ្ជីបង់លេខនិងចុះហត្ថលេខាសង្ខេបដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយរក្សាសៀវភៅបញ្ជីនោះទុកយ៉ាងតិច ៥ ឆ្នាំ ក្រោយកិច្ចប្រតិបត្តិការចុងក្រោយដែលបានកត់ត្រា ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចាត់មន្ត្រីរបស់ខ្លួនឱ្យទៅពិនិត្យមើលសៀវភៅបញ្ជីទាំងអស់នេះដល់ទីកន្លែង ។

## ផ្នែកទី ៥

## កាតព្វកិច្ចប្រុងប្រយ័ត្នរបស់អង្គការហិរញ្ញវត្ថុ

### មាត្រា ២២.-

គ្រឹះស្ថានឥណទាន និងស្ថាប័នហិរញ្ញវត្ថុទាំងឡាយ ត្រូវសួរបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជនមុននឹងធ្វើទំនាក់ទំនងកិច្ចការរកស៊ីជាមួយ ។ ត្រូវឃ្លាំមើលជាពិសេសបើមានប្រតិបត្តិការមិនប្រក្រតីឬស្មុគស្មាញ ត្រូវរក្សាទុកឯកសារទាំងឡាយទាក់ទងទៅនឹងអត្តសញ្ញាណនៃអតិថិជនរបស់ខ្លួន និងកិច្ចប្រតិបត្តិការដែលអ្នកទាំងនោះបានធ្វើ។ ត្រូវឱ្យបុគ្គលិករបស់ខ្លួនផ្សារភ្ជាប់ស្មារតីទៅនឹងការប្រយុទ្ធប្រឆាំងនិងការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ។

ល័ក្ខខ័ណ្ឌនៃការអនុវត្តន៍មាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៧

# ការរាវរកនិងការរាយការណ៍ប្រាប់ការសង្ស័យថាមានការសំអាតប្រាក់

## ផ្នែកទី ១

## បុគ្គលនិងអង្គការដែលត្រូវរាយការណ៍

### [១]មាត្រា ២៣ ថ្មី.-

គ្រឹះស្ថានឥណទាន ស្ថាប័នហិរញ្ញវត្ថុទាំងឡាយ និងបុគ្គលដទៃទៀត ដែលក្នុងការប្រព្រឹត្តវិជ្ជាជីវៈរបស់ខ្លួនបានធ្វើត្រួតពិនិត្យ ឬណែនាំឱ្យធ្វើកិច្ចប្រតិបត្តិការ ដែលបណ្តាលឱ្យមានចលនាទុនត្រូវរាយការណ៍អំពីទឹកប្រាក់ដែលខ្លួនសង្ស័យថា បានមកពីបទល្មើសទាំងឡាយ ដែលមានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់ មាត្រា ៣៣ ថ្មី មាត្រា ៣៧.២ ថ្មី ដល់ មាត្រា ៣៧.៤ ថ្មី

---

[១] មាត្រា ២៣ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

មាត្រា ៣៨.១ ថ្មី ដល់ មាត្រា ៤០ ថ្មី មាត្រា ៤២ ថ្មី មាត្រា ៤៣ និងមាត្រា ៤៤ ថ្មី ព្រមទាំងប្រកាសប្រាប់កិច្ចប្រតិបត្តិការទាក់ទិននឹងទឹកប្រាក់នោះ។ មេធាវីត្រូវរាយការណ៍តែអំពីកិច្ចប្រតិបត្តិការទាំងឡាយណា ដែលខ្លួនបានដឹងក្រៅពីការងារការពាររបស់ខ្លួន ។

គ្រឹះស្ថានឥណទាន ស្ថាប័នហិរញ្ញវត្ថុ មានកាតព្វកិច្ចរាយការណ៍អំពីកិច្ចប្រតិបត្តិការទាំងឡាយ ដែលមានចែងខាងលើ ទោះបីពុំអាចផ្អាកការអនុវត្តកិច្ចប្រតិបត្តិការទាំងនោះក៏ដោយ ឬទោះបីទឹកប្រាក់ដែលមានចែងខាងលើលេចឡើងក្រោយកិច្ចប្រតិបត្តិការបានសម្រេចក៏ដោយ ។

អង្គការ និងបុគ្គលទាំងឡាយ ដែលមានចែងក្នុងកថាខណ្ឌទីមួយ ក៏ត្រូវរាយការណ៍អំពីពត៌មានទាំងអស់ដែលបង្កើនការសង្ស័យ ឬធ្វើឱ្យបាត់ការសង្ស័យខាងដើម។

## ផ្នែកទី ២
## នីតិវិធីនៃការរាយការណ៍

### មាត្រា ២៤.-

គ្រឹះស្ថានឥណទាន ស្ថាប័នហិរញ្ញវត្ថុនិងបុគ្គលដទៃទៀត ដែលចែងក្នុងមាត្រាខាងលើ ត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ត្រូវប្រាប់ទៅគណៈកម្មការដែលបង្កើតឡើងក្នុងមាត្រា ២៥ ឱ្យផ្តល់ពត៌មានគ្រប់គ្រាន់ដើម្បីសម្រេចអំពីការចោទប្រកាន់ ។

### មាត្រា ២៥.-

ត្រូវបង្កើតគណៈកម្មការមួយប្រឆាំងនឹងការសំអាតប្រាក់ ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី ។

សមាសភាពនិងភារកិច្ចរបស់គណៈកម្មការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ផ្នែកទី ៣
# ការចាត់តាំងលើសេចក្ដីរាយការណ៍ដោយគណៈកម្មការ
# ប្រឆាំងនឹងការសំអាតប្រាក់

## មាត្រា ២៦.-

គណៈកម្មការប្រឆាំងនឹងការសំអាតប្រាក់ ត្រូវឆ្លើយថាបានទទួលសេចក្ដីរាយការណ៍ ក្នុងរយៈពេលកំណត់សម្រាប់អនុវត្តប្រតិបត្តិការខាងធនាគារឬខាងហិរញ្ញវត្ថុ ។ លិខិតឆ្លើយតបខាងលើនេះ អាចមានសេចក្ដីជំទាស់តម្រូវឱ្យផ្អាកកិច្ចប្រតិបត្តិការក្នុងរយៈពេលមិនលើសពី២៤ម៉ោង។ ប្រសិនបើការឆ្លើយតបឥតមានលើកឡើងនូវការប្ដឹងជំទាស់អ្វីទេ ឬក៏ថានៅពេលចប់រយៈពេលប្ដឹងទាស់ ហើយឥតមានសេចក្ដីសម្រេចណាមួយ បញ្ជាឱ្យមានវិធានការទប់ស្កាត់ដែលមានចែងក្នុងវាក្យខ័ណ្ឌបន្ទាប់មកដល់អ្នករាយការណ៍ទេ អ្នករាយការណ៍នេះអាចឱ្យអនុវត្តកិច្ចប្រតិបត្តិការបាន។

កាលបើពុំអាចកំណត់ប្រភពទឹកប្រាក់ក្នុងចិរវេលា២៤ម៉ោងបានទេ នោះប្រធានតុលាការសមត្ថកិច្ចតាមពាក្យស្នើសុំរបស់អយ្យការ ដែលទទួលបណ្ដឹងពីគណៈកម្មការប្រឆាំងនឹងការសំអាតប្រាក់ អាចបញ្ជាឱ្យខ្ទប់មូលនិធី គណនីនិងមូលប័ត្រ លើកលែងតែចៅក្រមស៊ើបអង្កេតបានបញ្ជាឱ្យខ្ទប់រួចហើយ ។

សេចក្ដីសម្រេចរបស់តុលាការ តាមពាក្យសុំរបស់អយ្យការ ត្រូវបានអនុវត្តភ្លាម ។

## មាត្រា ២៧.-

ពុំអាចមានការចោទប្រកាន់អំពីការរំលោភលើការសម្ងាត់នៃវិជ្ជាជីវៈទៅលើបុគ្គល ឬអ្នកដឹកនាំ ឬអ្នកទទួលបន្ទុកត្រួតពិនិត្យរបស់អង្គការដែលមានចែងនៅមាត្រា ២៣ ហើយដែលបានធ្វើសេចក្ដីរាយការណ៍ដោយសុទ្ធចិត្តដែលមានចែងក្នុងមាត្រានោះឡើយ ។

ពុំអាចប្ដឹងឱ្យទទួលខុសត្រូវខាងបទរដ្ឋប្បវេណីណាមួយបានឡើយ ហើយក៏ពុំអាចដាក់ទ័ណ្ឌកម្មខាងវិជ្ជាជីវៈណាមួយទៅលើបុគ្គល ឬអង្គការទាំងឡាយដែលបានធ្វើសេចក្ដីរាយការណ៍ដោយសុទ្ធចិត្តបានឡើយ ទោះបីការសង្កេតឬសេចក្ដីសម្រេចរបស់តុលាការបង្ហាញថាសេចក្ដីរាយការណ៍នោះឥតមានមូលដ្ឋានក៏ដោយ ។

## មាត្រា ២៨.-

គ្រឹះស្ថានឥណទានឬស្ថាប័នហិរញ្ញវត្ថុ ត្រូវរួចផុតពីការទទួលខុសត្រូវគ្រប់បែបយ៉ាង ហើយក៏ពុំអាចត្រូវបានចោទប្រកាន់ពីបទអាជ្ញាណាមួយទៅលើអ្នកដឹកនាំ ឬអ្នកទទួលបន្ទុកត្រួតពិនិត្យរបស់គ្រឹះស្ថានទាំងនោះបានឡើយ កាលបើកិច្ចប្រតិបត្តិការត្រូវបានធ្វើដូចដែលមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រា២៦ លើកលែងតែគ្រឹះស្ថានឬស្ថាប័ននោះមានការឃុបឃិតជាមួយម្ចាស់ប្រាក់ ឬម្ចាស់នៃកិច្ចប្រតិបត្តិការ ។

# ជំពូកទី ៨

# បទប្បញ្ញត្តិព្រហ្មទណ្ឌ

## [២]មាត្រា ២៩ ថ្មី.-

ដោយពុំទាន់គិតដល់ទោសទាំងឡាយ
ដែលមានចែងទុកសម្រាប់ជំនួញគ្រឿងញៀនខុសច្បាប់
និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងសម្រាប់ការសម្អាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់ :

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃដល់ ១ (មួយ) ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬទោសណាមួយនៃទោសទាំងពីរនេះ :

ក/- ជនណា អ្នកដឹកនាំ ឬអ្នកទទួលបន្ទុកត្រួតពិនិត្យរបស់អង្គការ ដែលមានចែងក្នុងមាត្រា ២៣ ថ្មី ដែលបានប្រាប់ម្ចាស់ប្រាក់ ឬម្ចាស់ប្រតិបត្តិការដែលមានចែងក្នុងមាត្រា ២៣ថ្មី អំពីសេចក្តីរាយការណ៍ដែលខ្លួនថា ខ្លួនមានកាតព្វកិច្ចត្រូវធ្វើ ឬអំពីផលវិបាកដែលម្ចាស់ប្រាក់ ឬម្ចាស់ប្រតិបត្តិការនោះ ត្រូវទទួលរង ឬក៏ថាដោយចេតនា ខ្លួនមិនធ្វើសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រានេះឡើយ។

---

[២] មាត្រា ២៩ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ខ/- ជនណាដែលបានប្រើអត្តសញ្ញាណក្លែងក្លាយ ដើម្បីធ្វើឱ្យសម្រេច ឬប៉ុនប៉ងធ្វើឱ្យបានសម្រេចនូវកិច្ចប្រតិបត្តិការដែលមានចែងក្នុងមាត្រា ១៨ និង ២១ នៃ ច្បាប់នេះ ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែដល់ ១ (មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀលដល់ ៥.០០០.០០០ (ប្រាំលាន)រៀល ជនណាដែលបំផ្លាញ ឬលួចសៀវភៅបញ្ជី ឬឯកសារ ដែលមាត្រា ២០ និង មាត្រា ២១ នៃច្បាប់នេះបានតម្រូវឱ្យរក្សាទុក ។

៣- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០(មួយសែន)រៀលដល់ ១.០០០.០០០(មួយលាន)រៀល :

ក/- ជនណាដែលបានធ្វើ ឬព្រមទទួលធ្វើការទូទាត់ជាប្រាក់ដែលមានចំនួនលើសពីចំនួនអនុញ្ញាត ។

ខ/- ជនណាដែលបានប្រព្រឹត្តល្មើសនឹងកាតព្វកិច្ច ត្រូវរាយការណ៍អំពីការផ្ទេរជាអន្តរជាតិនូវមូលនិធិ មូលប័ត្រ ឬរបស់មានតម្លៃទាំងឡាយដែលច្បាប់តម្រូវឱ្យរាយការណ៍ ។

គ/- អ្នកដឹកនាំ ឬអ្នកទទួលបន្ទុកប្តូរប្រាក់ផ្ទាល់ដៃ អ្នកទទួលបន្ទុកគ្រឹះស្ថានល្បែង គ្រឹះស្ថានឥណទាន និងស្ថាប័នហិរញ្ញវត្ថុ ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃមាត្រា១៩ ដល់ ២២ នៃច្បាប់នេះ ។

ជនណាដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ អាចត្រូវបានហាមឃាត់ជាស្ថាពរ ឬក្នុងរយៈពេលពី ៦(ប្រាំមួយ)ខែ ទៅ ៥(ប្រាំ) ឆ្នាំ មិនឱ្យប្រកបវិជ្ជាជីវៈ ដែលខ្លួនបានប្រព្រឹត្តល្មើសច្បាប់ ។

## ជំពូកទី ៩

## បទប្បញ្ញត្តិខាងវិន័យ

**មាត្រា ៣០.-**

កាលបើគ្រឹះស្ថានឥណទាននិងស្ថាប័នហិរញ្ញវត្ថុ ឬជនដែលមានចែងក្នុងមាត្រា២៣ សហគ្រាសប្តូរប្រាក់ផ្ទាល់ដៃ ឬគ្រឹះស្ថានល្បែងមិនបានបំពេញកាតព្វកិច្ចណាមួយដែលបានតម្រូវមកលើ

ខ្លួនដោយបទប្បញ្ញត្តិនៃច្បាប់នេះ ឬដោយអនុក្រឹត្យទាំងឡាយសម្រាប់អនុវត្តច្បាប់នេះបណ្តាលពីកំហុសធ្ងន់ធ្ងរ ខ្វះការប្រុងប្រយ័ត្នឬខ្វះការរៀបចំនីតិវិធីផ្ទៃក្នុង អាជ្ញាធរខាងវិន័យអាចចាត់វិធានការដោយបញ្ញត្តិក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងបទបញ្ញាខាងវិជ្ជាជីវៈ ឬខាងរដ្ឋបាល។

# ជំពូកទី ១០

# ការចោទប្រកាន់និងមូលទោស

## ផ្នែកទី ១

## គ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ

## ( តារាង I និង II )

### [៣]មាត្រា ៣១ ថ្មី.-

ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ញាទាក់ទងនឹងការដាំរុក្ខជាតិញៀន ដែលបណ្តលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ :

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែដល់ ២ (ពីរ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ដល់ ៤.០០០.០០០ (បួនលាន)រៀល ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀលដល់ ១០.០០០.០០០ (ដប់លាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសនេះធ្វើឡើង ក្នុងគោលបំណងចែកចាយផលិត ឬធ្វើពាណិជ្ជកម្ម ។

---

[៣] មាត្រា ៣១ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

## [៤]មាត្រា ៣២.១ ថ្មី.~

១- ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការផលិតគ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស នឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀលដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំដល់ ១០(ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ ៖

ក- ប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- បើការផលិតជ័រអាភៀន ឬការ៉ូកា មានបរិមាណសុទ្ធចាប់ពី ៥០០ (ប្រាំរយ) ក្រាម រហូតដល់ក្រោម ១ (មួយ) គីឡូក្រាម ។

គ- បើការផលិតជ័រកញ្ឆា មានបរិមាណសុទ្ធចាប់ពី ១(មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម ឬប្រេងកញ្ឆា មានបរិមាណសុទ្ធចាប់ពី ៥០០ (ប្រាំរយ) ក្រាម រហូតដល់ក្រោម ១ (មួយ) គីឡូក្រាម ។

ឃ- បើការផលិតម៉រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ៥ (ប្រាំ) ក្រាម រហូតដល់ក្រោម ៣០ (សាមសិប) ក្រាម ។

ង- បើការផលិតបណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី២០ (ម្ភៃ) ក្រាម រហូតដល់ក្រោម ១០០ (មួយរយ) ក្រាម ។

ច- បើការផលិតសារធាតុញៀន ចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុច ខ ដល់ ចំណុច ង កថាខណ្ឌទី ២ នៃមាត្រានេះ ។

---

[៤] មាត្រា ៣២ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

៣- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន)រៀល ដល់ ៤០.០០០.០០០ (សែសិបលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ ៖

ក- មានលក្ខណៈជាមុខរបរ ។

ខ- បើការផលិតជ័រអាភៀន ឬការ៉ូកា មានបរិមាណសុទ្ធចាប់ពី ១(មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម ។

គ- បើការផលិតជ័រកញ្ឆា មានបរិមាណសុទ្ធចាប់ពី ២ (ពីរ) គីឡូក្រាម រហូតដល់ក្រោម ៤(បួន) គីឡូក្រាម ឬប្រេងកញ្ឆា មានបរិមាណសុទ្ធចាប់ពី ១ (មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម ។

ឃ- បើការផលិត ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ៣០ (សាមសិប) ក្រាម រហូតដល់ក្រោម ១០០ (មួយរយ) ក្រាម ។

ង- បើការផលិតបណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ផ្សេងទៀត មានបរិមាណសុទ្ធ ចាប់ពី ១០០ (មួយរយ) ក្រាម រហូតដល់ក្រោម ៣០០ (បីរយ) ក្រាម ។

ច- បើការផលិតសារធាតុញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចខ ដល់ចំណុចង កថាខណ្ឌទី ៣ នៃមាត្រានេះ ។

៤- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០(ម្ភៃ) ឆ្នាំដល់ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន)រៀល ដល់ ១០០.០០០.០០០(មួយរយលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ ៖

ក- បើការផលិតជ័រអាភៀន ឬការ៉ូកា មានបរិមាណសុទ្ធចាប់ពី ២ (ពីរ) គីឡូក្រាម ឡើងទៅ ។

ខ- បើការផលិតជ័រកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៤ (បួន) គីឡូក្រាមឡើងទៅ ឬប្រេងកញ្ឆា មានបរិមាណសុទ្ធចាប់ពី ២ (ពីរ) គីឡូក្រាមឡើងទៅ ។

គ- បើការផលិតម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ១០០ (មួយរយ) ក្រាមឡើងទៅ ។

ឃ- បើការផលិតបណ្ដាសារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ៣០០ (បីរយ) ក្រាមឡើងទៅ ។

ង- បើការផលិតសារធាតុញៀន ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុច ក ដល់ចំណុច ឃ កថាខណ្ឌទី ៤ នៃមាត្រានេះ ។

## មាត្រា ៣២.២ ថ្មី..

១- ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការនាំចេញ នាំចូល ដឹកជញ្ជូនជាអន្តរជាតិនូវគ្រឿងញៀន ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស នឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

២- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំដល់ ១០(ដប់) ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- ជ័រអាភៀន ឬការ៉ូកា មានបរិមាណសុទ្ធចាប់ពី ៥០០ (ប្រាំរយ) ក្រាម រហូតដល់ក្រោម ១ (មួយ) គីឡូក្រាម ។

គ- ជ័រកញ្ឆាមានបរិមាណសុទ្ធចាប់ពី ១(មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម ឬប្រេងកញ្ឆា មានបរិមាណសុទ្ធចាប់ពី ៥០០ (ប្រាំរយ) ក្រាម រហូតដល់ក្រោម ១ (មួយ) គីឡូក្រាម ។

ឃ- ម៉រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ៥ (ប្រាំ)ក្រាម រហូតដល់ក្រោម ៣០ (សាមសិប) ក្រាម ។

ង- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ១០ (ដប់) គីឡូក្រាម រហូតដល់ក្រោម ២៥ (ម្ភៃប្រាំ) គីឡូក្រាម ។

ច- ផ្លែអាភៀនស្រស់ មានបរិមាណចាប់ពី ១០ (ដប់) គីឡូក្រាម រហូតដល់ក្រោម ៥០ (ហាសិប) គីឡូក្រាម ។

ឆ- ផ្លែអាភៀនស្ងួត មានបរិមាណចាប់ពី ៥០ (ហាសិប) គីឡូក្រាម រហូតដល់ក្រោម ២០០ (ពីររយ) គីឡូក្រាម ។

ជ- បណ្ដាសារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ២០(ម្ភៃ) ក្រាម រហូតដល់ក្រោម ១០០ (មួយរយ) ក្រាម ។

ឈ- សារធាតុញៀន ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុច ខ ដល់ចំណុច ជ កថាខណ្ឌទី ២ នៃមាត្រានេះ ។

៣- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំដល់ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ ពី ២០.០០០.០០០ (ម្ភៃលាន)រៀល ដល់ ៤០.០០០.០០០ (សែសិបលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ជ័រអាភៀន ឬការកូកា មានបរិមាណសុទ្ធចាប់ពី ១ (មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម ។

ខ- ជ័រកញ្ឆាមានបរិមាណសុទ្ធចាប់ពី ២ (ពីរ) គីឡូក្រាម រហូតលដល់ក្រោម ៤ (បួន) គីឡូក្រាម ឬប្រេងកញ្ឆា មានបរិមាណសុទ្ធចាប់ពី ១ (មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម ។

គ- ម៉រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ៣០ (សាមសិប) ក្រាម រហូតដល់ក្រោម ១០០ (មួយរយ) ក្រាម ។

ឃ- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ២៥ (ម្ភៃប្រាំ) គីឡូក្រាម រហូតដល់ក្រោម ៧៥ (ចិតសិបប្រាំ) គីឡូក្រាម ។

ង- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ៥០ (ហាសិប) គីឡូក្រាម រហូតដល់ក្រោម ១៥០ (មួយរយហាសិប) គីឡូក្រាម ។

ច- ផ្លែអាភៀនស្ងួត មានបរិមាណចាប់ពី ២០០ (ពីររយ) គីឡូក្រាម រហូតដល់ក្រោម ៦០០ (ប្រាំមួយរយ) គីឡូក្រាម ។

ឆ- បណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតមានបរិមាណសុទ្ធចាប់ពី ១០០ (មួយរយ) ក្រាម រហូតដល់ក្រោម ៣០០ (បីរយ) ក្រាម ។

ជ- មានសារធាតុញៀនចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុច ក ដល់ចំណុច ឆ កថាខណ្ឌទី ៣ នៃមាត្រានេះ ។

៤- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០(ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន)រៀលដល់ ១០០.០០០.០០០(មួយរយលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ជ័រអាភៀន ឬការកូកា មានបរិមាណសុទ្ធចាប់ពី ២ (ពីរ) គីឡូក្រាម ឡើងទៅ ។

ខ- ជ័រកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៤ (បួន) គីឡូក្រាម ឬប្រេងកញ្ឆា មានបរិមាណសុទ្ធចាប់ពី ២ (ពីរ) គីឡូក្រាមឡើងទៅ ។

គ - ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ១០០ (មួយរយ) ក្រាមឡើងទៅ ។

ឃ- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៧៥ (ចិតសិបប្រាំ) គីឡូក្រាមឡើងទៅ ។

ង- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ១៥០ (មួយរយហាសិប) គីឡូក្រាមឡើងទៅ ។

ច- ផ្លែអាភៀនស្ងួត មានបរិមាណចាប់ពី ៦០០ (ប្រាំមួយរយ) គីឡូក្រាមឡើងទៅ ។

ឆ- បណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតមានបរិមាណសុទ្ធចាប់ពី ៣០០ (បីរយ) ក្រាមឡើងទៅ ។

ជ- សារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុច ក ដល់ចំណុច ឆ កថាខណ្ឌទី៤ នៃមាត្រានេះ ។

## [៥] មាត្រា ៣៣ ថ្មី.-

១- ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ញាទាក់ទងនឹងការកាន់កាប់ ការរក្សាទុក ការស្នើផ្តល់ឱ្យដាក់លក់ ការប្រគល់ឱ្យទោះក្នុងឋានៈអ្វីក៏ដោយ ការជួញដូរ ការធ្វើរបរជើងសារ ការដាក់លក់ ការលក់ ការទិញ ការដឹកជញ្ជូន ការដណ្តើមកាន់កាប់ ឬការប្រើប្រាស់នូវគ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោស ពិន័យជាប្រាក់ ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀល ដល់ ២០.០០០.០០០(ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- ជ័រអាភៀន ឬការ៉ូកា មានបរិមាណសុទ្ធចាប់ពី ៥០០ (ប្រាំរយ) ក្រាម រហូតដល់ក្រោម ១ (មួយ) គីឡូក្រាម ។

គ- ជ័រកញ្ឆាមានបរិមាណសុទ្ធចាប់ពី ១ (មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម ឬប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៥០០ (ប្រាំរយ) ក្រាម រហូតដល់ក្រោម ១ (មួយ) គីឡូក្រាម។

---

[៥] មាត្រា ៣៣ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ឃ- ម៉រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ៥ (ប្រាំ) ក្រាម រហូតដល់ក្រោម ៣០ (សាមសិប) ក្រាម ។

ង- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ១០ (ដប់) គីឡូក្រាម រហូតដល់ក្រោម ២៥ (ម្ភៃប្រាំ) គីឡូក្រាម ។

ច- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ១០ (ដប់) គីឡូក្រាម រហូតដល់ក្រោម ៥០ (ហាសិប) គីឡូក្រាម ។

ឆ- ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ៥០ (ហាសិប) គីឡូក្រាម រហូតដល់ក្រោម ២០០ (ពីររយ) គីឡូក្រាម ។

ជ- បណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតមានបរិមាណសុទ្ធចាប់ពី ២០(ម្ភៃ) ក្រាម រហូតដល់ក្រោម ១០០ (មួយរយ) ក្រាម ។

ឈ- មានសារធាតុញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពី ចំណុច ខ ដល់ចំណុច ជ កថាខណ្ឌទី២ នៃមាត្រានេះ ។

៣- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០.០០០.០០០(ម្ភៃលាន)រៀលដល់ ៤០.០០០.០០០(សែសិបលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ជ័រអាភៀន ឬការកូកា មានបរិមាណសុទ្ធចាប់ពី១ (មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម ។

ខ- ជ័រកញ្ឆាមានបរិមាណសុទ្ធចាប់ពី ២(ពីរ) គីឡូក្រាម រហូតដល់ក្រោម ៤ (បួន) គីឡូក្រាម ឬប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ១ (មួយ) គីឡូក្រាម រហូតដល់ក្រោម ២ (ពីរ) គីឡូក្រាម។

គ- ម៉រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ៣០(សាមសិប) ក្រាម រហូតដល់ក្រោម ១០០ (មួយរយ) ក្រាម ។

ឃ- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ២៥ (ម្ភៃប្រាំ) គីឡូក្រាម រហូតដល់ក្រោម ៧៥ (ចិតសិបប្រាំ) គីឡូក្រាម ។

ង- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ៥០ (ហាសិប) គីឡូក្រាម រហូតដល់ក្រោម ១៥០ (មួយរយហាសិប) គីឡូក្រាម ។

ច- ផ្លែអាភៀនស្ងួត មានបរិមាណចាប់ពី ២០០ (ពីររយ) គីឡូក្រាម រហូតដល់ក្រោម ៦០០ (ប្រាំមួយរយ) គីឡូក្រាម ។

ឆ- បណ្ដាសារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតមានបរិមាណសុទ្ធចាប់ពី ១០០ (មួយរយ) ក្រាម រហូតដល់ក្រោម ៣០០ (បីរយ) ក្រាម ។

ជ- មានសារធាតុញៀន ចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុច ក ដល់ចំណុច ឆ កថាខណ្ឌទី៣ នៃមាត្រានេះ ។

៤- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០(ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប)ឆ្នាំ ឬអស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពី ៤០.០០០.០០០ (សែសិបលាន)រៀល ដល់ ១០០.០០០.០០០(មួយរយលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ជ័រអាភៀន ឬការ៉ូកា មានបរិមាណសុទ្ធចាប់ពី ២(ពីរ) គីឡូក្រាមឡើងទៅ ។

ខ- ជ័រកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៤(បួន) គីឡូក្រាមឡើងទៅ ឬប្រេងកញ្ឆា មានបរិមាណសុទ្ធ ចាប់ពី ២ (ពីរ) គីឡូក្រាមឡើងទៅ ។

គ- ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ១០០ (មួយរយ) ក្រាមឡើងទៅ ។

ឃ- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៧៥ (ចិតសិបប្រាំ) គីឡូក្រាមឡើងទៅ ។

ង- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ១៥០(មួយរយហាសិប) គីឡូក្រាមឡើងទៅ ។

ច- ផ្លែអាភៀនស្ងួត មានបរិមាណចាប់ពី ៦០០ (ប្រាំមួយរយ) គីឡូក្រាមឡើងទៅ ។

ឆ- បណ្ដាសារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតមានបរិមាណសុទ្ធចាប់ពី ៣០០ (បីរយ) ក្រាមឡើងទៅ។

ជ- សារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ចាប់ពី ពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀន

ដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុច ក ដល់ចំណុច ឆ កថាខណ្ឌទី៤ នៃមាត្រានេះ ។

## [៦] មាត្រា ៣៤ ថ្មី.-

ជនណាជាអ្នកផ្ដើមគំនិត ឬអ្នកដឹកនាំក្រុមឧក្រិដ្ឋជន ដែលមានរចនាសម្ព័ន្ធចាត់តាំងក្នុងការប្រព្រឹត្តបទល្មើសណាមួយ ឬច្រើនដែលមានចែងក្នុងមាត្រា៣១ ថ្មី ដល់មាត្រា៣៣ ថ្មី និង មាត្រា៣៩ ថ្មី ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ចាប់ពី១០០.០០០.០០០(មួយរយលាន)រៀលដល់ ៥០០.០០០.០០០ (ប្រាំរយលាន)រៀល។

## [៧] មាត្រា ៣៥.១ ថ្មី.-

១- ជនណាចាត់ចែង បង្ខំ ញុះញង់ អូសទាញ ឬបោកបញ្ឆោតដោយចេតនាដល់ជនណាម្នាក់ឱ្យប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

២- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និងត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- បានប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- ដោយមូលហេតុគំនុំ ឬព្យាបាទ ។

គ- ចំពោះស្ត្រីដែលជនល្មើសនោះដឹងថាមានគភ៌ ។

ឃ- ចំពោះមនុស្សច្រើននាក់ ។

---

[៦] មាត្រា ៣៤ ( និរាករណ៍ដោយច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[៧] មាត្រា ៣៥ ( និរាករណ៍ដោយច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

**មាត្រា ៣៥.២ ថ្មី.-**

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ចំពោះ :

ក- ជនណាដែលសម្រួលដោយចេតនាឱ្យជនណាម្នាក់ ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ទោះយកថ្លៃក្តី មិនយកថ្លៃក្តី ។

ជននោះមានជាអាទិ៍គឺៈ អ្នកម្ចាស់ផ្ទះ បណ្ណាធិការ នាយក អាជីវករ ទោះក្នុងឋានៈជាអ្វីក៏ដោយនៃសណ្ឋាគារ ផ្ទះឈ្នួល មានចលនវត្ថុសម្រាប់ប្រើប្រាស់ កន្លែងទទួលឱ្យស្នាក់នៅ និងបរិភោគ តៀមលក់ភេសជ្ជៈ ភោជនីយដ្ឋាន ក្លឹបសមាគមកំសាន្ត កន្លែងរាំច្រៀង កន្លែងទស្សនីយភាព ឬកន្លែងអ្វីមួយ បើកសម្រាប់សាធារណជន ឬប្រើប្រាស់ដោយសារធារណជន ។ល។ ដែលអត់ឱនឱ្យប្រើប្រាស់គ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរនៅក្នុងគ្រឹះស្ថានទាំងនោះ ឬសាខារបស់គ្រឹះស្ថានទាំងនោះ ឬនៅក្នុងកន្លែងនោះ ។

ខ- ជនណាដែលដឹងជាមុនហើយ ប៉ុន្តែនៅតែចេញវេជ្ជបញ្ជាបំពេញចិត្តឱ្យប្រើប្រាស់គ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

គ- ជនណាដែលដឹងថា វេជ្ជបញ្ជាមានលក្ខណៈមិនត្រឹមត្រូវ ឬធ្វើឡើងដោយបំពេញចិត្តឱ្យអ្នកប្រើប្រាស់ ប៉ុន្តែនៅតែផ្តល់ឱ្យអ្នកយកមកទិញនូវគ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

ឃ- ជនណាដែលយកវេជ្ជបញ្ជាមិនត្រឹមត្រូវ ឬសម្រាប់បំពេញចិត្តឱ្យអ្នកប្រើប្រាស់យកទៅឱ្យគេផ្តល់ ឬប៉ុនប៉ងធ្វើឱ្យគេផ្តល់គ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

ង- ជនណាដែលលួចដាក់គ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរក្នុងអាហារ ក្នុងភេសជ្ជៈ ឬក្នុងសម្ភារៈផ្សេងទៀត ដោយមិនឱ្យអ្នកបរិភោគ ឬអ្នកប្រើប្រាស់ដឹង ។

ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

២-	ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និងត្រូវពិន័យជាប្រាក់ ពី ១០.០០០.០០០ (ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក-	បានប្រព្រឹត្តបទល្មើសច្រើនដង ។

ខ-	ចំពោះមនុស្សច្រើននាក់ ។

គ-	ចំពោះស្ត្រីដែលជនល្មើសនោះដឹងថាមានគភ៌ ។

## ផ្នែកទី ២
## ការចែកឱ្យដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន

### [៨]មាត្រា ៣៦ ថ្មី.-

១-	ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការចែក ឬផ្តល់នូវគ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ទៅឱ្យជនណាម្នាក់ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២(ពីរ)ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី១.០០០.០០០ (មួយលាន)រៀលដល់ ៤.០០០.០០០ (បួនលាន)រៀល ។

២-	ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងអាចទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀលដល់ ១០.០០០.០០០(ដប់លាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក-	បានប្រព្រឹត្តបទល្មើសច្រើនដង ។

ខ-	ចំពោះមនុស្សច្រើននាក់ ។

គ-	ចំពោះស្ត្រីដែលជនល្មើសនោះដឹងថាមានគភ៌ ។

---

[៨] មាត្រា ៣៦ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

# ផ្នែកទី ៣

# គ្រឿងញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់

## [៩] មាត្រា ៣៧.១ ថ្មី.-

១- ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការដាំរុក្ខជាតិញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៣(បី) ខែដល់ ១ (មួយ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៦០០.០០០ (ប្រាំមួយសែន)រៀលដល់ ២.០០០.០០០(ពីរលាន)រៀល ។

២- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៣ (បី)ឆ្នាំ ក្នុងករណីដែលការប្រព្រឹត្តបទល្មើសនេះធ្វើឡើងក្នុងគោលបំណង ចែកចាយ ផលិត ឬធ្វើពាណិជ្ជកម្ម។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

## មាត្រា ៣៧.២ ថ្មី.-

១- ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការផលិតគ្រឿងញៀន ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ដល់ ៣ (បី) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

២- ត្រូវផ្ដន្ទាសទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលដល់ ១០.០០០.០០០ (ដប់លាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ប្រព្រឹត្តបទល្មើសច្រើនដង ។

---

[៩] មាត្រា ៣៧ (និរាករណ៍ដោយច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ខ- បណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ មានបរិមាណសុទ្ធ ចាប់ពី ១០០ (មួយរយ) ក្រាម រហូតដល់ក្រោម ៣០០ (បីរយ) ក្រាម ។

គ- មានសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ចាប់ពី ពីរប្រភេទឡើងទៅ ហើយបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុច ខ ខាងលើនេះ ។

៣- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០ (ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក - បណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ មានបរិមាណសុទ្ធ ចាប់ពី ៣០០ (បីរយ) ក្រាមឡើងទៅ ។

ខ- មានសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចាប់ពីពីរប្រភេទឡើងទៅ ហើយបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី៣ នៃមាត្រានេះ ។

## មាត្រា ៣៧.៣ ថ្មី.-

១- ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការនាំចេញ ការនាំចូល ការដឹកជញ្ជូនជាអន្តរជាតិនូវគ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៣ (បី) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស នឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀលដល់ ១០.០០០.០០០ (ដប់លាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- បណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ មានបរិមាណសុទ្ធ ចាប់ពី ១០០ (មួយរយ) ក្រាម រហូតដល់ក្រោម ៣០០ (បីរយ) ក្រាម។

គ- មានសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ចាប់ពី ពីរប្រភេទឡើងទៅ ហើយបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុច ខ ខាងលើនេះ ។

៣- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំដល់ ១០(ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀលដល់ ២០.០០០.០០០(ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- បណ្តាសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ មានបរិមាណសុទ្ធ ចាប់ពី ៣០០ (បីរយ) ក្រាមឡើងទៅ ។

ខ- មានសារធាតុញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចាប់ពីពីរប្រភេទឡើងទៅ ហើយបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី៣ នៃមាត្រានេះ ។

## មាត្រា ៣៧.៤ ថ្មី.-

១- ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការកាន់កាប់ ការរក្សាទុក ការស្នើផ្តល់ឱ្យដាក់លក់ ការផ្តល់ ការប្រគល់ឱ្យទោះក្នុងឋានៈអ្វីក៏ដោយ ការដាក់លក់ ការលក់ ការទិញ ការផ្ញើទៅឱ្យ ការជួញដូរ ការធ្វើបរដើងសារ ការដឹកជញ្ជូន ការបញ្ជូន ការដណ្តើមកាន់កាប់ ឬការប្រើប្រាស់នូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ដល់ ៣ (បី) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀលដល់ ១០.០០០.០០០

(ដប់លាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- បណ្ដាសារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ មានបរិមាណសុទ្ធ ចាប់ពី ១០០ (មួយរយ) ក្រាម រហូតដល់ក្រោម ៣០០ (បីរយ) ក្រាម ។

គ- មានសារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ ចាប់ពី ពីរប្រភេទឡើងទៅ ហើយបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុច ខ ខាងលើនេះ ។

៣- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និងត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០ (ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- បណ្ដាសារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ មានបរិមាណសុទ្ធ ចាប់ពី ៣០០ (បីរយ) ក្រាមឡើងទៅ ។

ខ- មានសារធាតុញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី៣ នៃមាត្រានេះ ។

## មាត្រា ៣៧.៥ ថ្មី.-

១- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ខែ ដល់ ១(មួយ) ឆ្នាំ ជនណាដែលបានចាត់ចែង ញុះញង់ បង្ខំ អូសទាញ ឬបោកបញ្ឆោតដោយចេតនា ឱ្យជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ ឬសារធាតុដែលមានឥទ្ធិពលដូចគ្នា។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៦០០.០០០ (ប្រាំមួយសែន)រៀលដល់ ២.០០០.០០០ (ពីរលាន)រៀល ។

២- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ៦.០០០.០០០

(ប្រាំមួយលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- បានប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- ចំពោះមនុស្សច្រើននាក់ ។

គ- ចំពោះស្ត្រីដែលជនល្មើសនោះដឹងថាមានគភ៌ ។

## មាត្រា ៣៧.៦.~ ថ្មី

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ដល់ ១(មួយ) ឆ្នាំ ជនណាដែលសម្រួលដោយចេតនា ឱ្យជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ទោះយកថ្លៃ ឬមិនយកថ្លៃក្តី ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ ពី ២០០.០០០ (ពីរសែន)រៀលដល់ ២.០០០.០០០ (ពីរលាន)រៀល ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- បានប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- ចំពោះមនុស្សច្រើននាក់ ។

គ- ចំពោះស្ត្រីដែលជនល្មើសនោះដឹងថាមានគភ៌ ។

# ផ្នែកទី ៤

## សារធាតុសម្រាប់ផ្សំធ្នាំញៀន (តារាង IV)

## បរិក្ខារ និងសម្ភារៈ

### [១០]មាត្រា ៣៨.១ ថ្មី.-

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំដល់ ៥(ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី៤.០០០.០០០ (បួនលាន)រៀលដល់ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះជនណាផលិត នាំចូល នាំចេញ ដឹកជញ្ជូន ផ្តល់ឱ្យលក់ ជួញដូរ ចែកចាយ ប្រគល់ឱ្យ ទោះបីក្នុងឋានៈជាអ្វីក៏ដោយ ផ្ញើទៅឱ្យ បញ្ជូនទិញ ឬរក្សាទុកនូវសារធាតុសម្រាប់ផ្សំគ្រឿងញៀន ក្នុងគោលដៅយកទៅផលិត ឬធ្វើដោយខុសច្បាប់ នូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ឬមួយបានដឹងច្បាស់ថា សារធាតុទាំងនោះ នឹងត្រូវបានប្រើប្រាស់សម្រាប់គោលដៅខាងលើ ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំដល់ ១០(ដប់)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- បានប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- មានលក្ខណៈជាមុខរបរ ។

គ- សារធាតុសម្រាប់ផ្សំគ្រឿងញៀនមានបរិមាណសុទ្ធចាប់ពី ១(មួយ) គីឡូក្រាម រហូតដល់ក្រោម ៥ (ប្រាំ) គីឡូក្រាម ។

៣- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០.០០០.០០០(ម្ភៃលាន)រៀលដល់ ៤០.០០០.០០០ (សែសិបលាន) រៀល បើសារធាតុសម្រាប់ផ្សំគ្រឿងញៀនមានបរិមាណសុទ្ធ ចាប់ពី ៥ (ប្រាំ) គីឡូក្រាម រហូតដល់ក្រោម ១០ (ដប់) គីឡូក្រាម ។

---

[១០] មាត្រា ៣៨ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

៤- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ)ឆ្នាំ ដល់ ៣០ (សាបសិប) ឆ្នាំ ឬ អស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន)រៀលដល់ ១០០.០០០.០០០ (មួយរយលាន)រៀល បើសារធាតុសម្រាប់ផ្សំគ្រឿងញៀន មានបរិមាណសុទ្ធ ចាប់ពី ១០ (ដប់) គីឡូក្រាមឡើងទៅ ។

## មាត្រា ៣៨.២ ថ្មី.-

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះ ជនណាផលិត នាំចូល នាំចេញ ដឹកជញ្ជូន ផ្តល់ឱ្យលក់ ជួញដូរ ចែកចាយ ប្រគល់ឱ្យទោះបីក្នុងឋានៈជាអ្វីក៏ដោយ ផ្ញើរទៅឱ្យ បញ្ជូនទិញ ឬរក្សាទុកនូវបរិក្ខារ និងសម្ភារៈក្នុងគោលដៅផលិត ឬធ្វើដោយខុសច្បាប់នូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬបណ្តាលឱ្យមានគ្រោះថ្នាក់ ឬដោយបានដឹងច្បាស់ថាបរិក្ខារ និងសម្ភារៈនោះ នឹងត្រូវបានប្រើប្រាស់សម្រាប់គោលដៅខាងលើ ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំដល់ ១០(ដប់)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- បានប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- មានលក្ខណៈជាមុខរបរ ។

គ- បរិក្ខារ និងសម្ភារៈដែលជាមុខសញ្ញានៃបទល្មើស មានបរិមាណ និងតម្លៃច្រើន ។

## ផ្នែកទី ៥
## ការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់

### [១១] មាត្រា ៣៩ ថ្មី.-

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែដល់ ២ (ពីរ)ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀលដល់ ៤.០០០.០០០ (បួនលាន)រៀលចំពោះ :

ក- ជនណាដែលផ្ទេរធនធាន ឬទ្រព្យសម្បត្តិដោយចេតនា ដែលបានមកពីបទល្មើសដូចមានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់មាត្រា ៣៦ ថ្មី និងមាត្រា ៣៧.២ ថ្មី ដល់មាត្រា ៣៨.២ ថ្មី នៃច្បាប់នេះ ក្នុងគោលបំណងលាក់បាំង ឬក្លែងបួសគល់ខុសច្បាប់នៃធនធាន ឬទ្រព្យសម្បត្តិទាំងនោះ ឬដើម្បីជួយជនប្រព្រឹត្តបទល្មើសឱ្យរួចពីទោសទាំងឡាយដែលកើតមានឡើងពីអំពើរបស់ខ្លួន ។

ខ- ជនណាដែលជួយលាក់បាំង ឬក្លែងប្រភេទបួសគល់ ទីកន្លែង ការចាត់ចែងចលនា ឬកម្មសិទ្ធិពិតប្រាកដនៃធនធាន ទ្រព្យសម្បត្តិ ឬសិទ្ធិទាំងឡាយដែលពាក់ព័ន្ធនឹងធនធាន និងទ្រព្យសម្បត្តិ ដែលបានមកពីបទល្មើសណាមួយដែលចែងក្នុងចំណុច ក ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀលដល់ ១០.០០០.០០០ (ដប់លាន)រៀល បើធនធាន ឬទ្រព្យសម្បត្តិនោះមានតម្លៃ ចាប់ពី៤០.០០០.០០០(សែសិបលាន)រៀល រហូតដល់ក្រោម ២០០.០០០.០០០(ពីរយលាន)រៀល ។

៣- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០(ដប់លាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល បើធនធាន ឬទ្រព្យសម្បត្តិនោះមានតម្លៃ ចាប់ពី ២០០.០០០.០០០ (ពីររយលាន)រៀល រហូតដល់ក្រោម ៤០០.០០០.០០០ (បួនរយលាន)រៀល ។

---

[១១] មាត្រា ៣៩ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

៤- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់)ឆ្នាំដល់២០(ម្ភៃ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន)រៀលដល់ ៤០.០០០.០០០(សែសិបលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- មានលក្ខណៈជាមុខរបរ ។

គ- ប្រព្រឹត្តបទល្មើសដោយប្រើមធ្យោបាយ វិធីសាស្ត្រ ឬឧបាយកលស្មុគស្មាញដើម្បីរារាំងដល់ការស៊ើបអង្កេត ។

ឃ- បើធនធាន ឬទ្រព្យសម្បត្តិមានតម្លៃចាប់ពី ៤០០.០០០.០០០(បួនរយលាន)រៀល រហូតដល់ក្រោម ៨០០.០០០.០០០ (ប្រាំបីរយលាន)រៀល ។

៥- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០(ម្ភៃ) ឆ្នាំដល់ ៣០ (សាមសិប)ឆ្នាំ ឬអស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤០.០០០.០០០(សែសិបលាន)រៀលដល់១០០.០០០.០០០(មួយរយលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ប្រព្រឹត្តបទល្មើសមានលក្ខណៈជាអន្តរជាតិ ឬឆ្លងប្រទេស ។

ខ- បើធនធាន ឬទ្រព្យសម្បត្តិមានតម្លៃចាប់ពី ៨០០.០០០.០០០ (ប្រាំបីរយលាន)រៀលឡើងទៅ ។

## ផ្នែកទី ៦

## ការទិញ ការរក្សាទុក ឬការប្រើប្រាស់ដោយដឹងហេតុផលនៃធនធាន និងទ្រព្យសម្បត្តិដែលបានមកពីបទល្មើស

### [១២]មាត្រា ៤០ ថ្មី.-

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំដល់ ៥(ប្រាំ) ឆ្នាំ និងអាចទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀលដល់ ១០.០០០.០០០

[១២] មាត្រា ៤០ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

(ដប់លាន) រៀល ជនណាដែលបានទិញ រក្សាទុក ទទួលផលកម្រៃ ឬប្រើប្រាស់តាមបែបណាក៏ដោយ នូវទ្រព្យសម្បត្តិ និងធនធាន ដែលខ្លួនដឹងថាបានមកពីការប្រព្រឹត្តបទល្មើសណាមួយនៃមាត្រា ៣២.១ ថ្មី ដល់ មាត្រា ៣៦ ថ្មី និងមាត្រា ៣៧.២ ថ្មី ដល់មាត្រា៣៩ ថ្មី នៃច្បាប់នេះ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០(ដប់លាន)រៀលដល់ ២០.០០០.០០០(ម្ភៃលាន)រៀល កាលបើបទល្មើសនេះប្រព្រឹត្តឡើងជាទម្លាប់ ។

អតិបរមានៃទោសពិន័យ អាចស្មើនឹងតម្លៃនៃទ្រព្យសម្បត្តិដែលជាមុខសញ្ញានៃបទល្មើសនេះ ក្នុងករណីដែលតម្លៃនៃទ្រព្យសម្បត្តិនេះលើសពីចំនួនប្រាក់ពិន័យ ដែលបានកំណត់ក្នុងកថាខណ្ឌទាំងពីរខាងលើ ។

# ជំពូកទី ១១

# បទប្បញ្ញត្តិរួមចំពោះបទល្មើសផ្សេងៗ

## ផ្នែកទី ១

## ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនិងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

### [១៣]មាត្រា ៤១ ថ្មី.-

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ ចំពោះជនណា ដែលបានញុះញង់ តាមមធ្យោបាយណាក៏ដោយ ទោះដោយផ្ទាល់ ឬដោយប្រយោល ឱ្យប្រព្រឹត្ត បទល្មើសណាមួយដែលមានចែងក្នុងមាត្រា ៣១ ថ្មី ដល់មាត្រា៤០ ថ្មី នៃច្បាប់នេះ បើការញុះញង់ មិនបានសម្រេចផល ។

២- ត្រូវផ្តន្ទាទោសដូចចារីចំពោះអ្នកញុះញង់ ប្រសិនបើការញុះញង់នោះបានសម្រេចផល ។

---

[១៣] មាត្រា ៤១ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

## ផ្នែកទី ២
## ការប៉ុនប៉ងប្រព្រឹត្តបទល្មើស ការរួមគ្នាឬការព្រមព្រៀងគ្នា

### [១៤]មាត្រា ៤២ ថ្មី.–

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសទាំងឡាយ ដែលមានចែងក្នុងមាត្រា ៣១ថ្មី ដល់ មាត្រា ៤០ ថ្មី នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចការប្រព្រឹត្តបទល្មើសបានសម្រេចដែរ។

ការរួមគ្នា ឬការព្រមព្រៀងគ្នាដើម្បីប្រព្រឹត្តបទល្មើសណាមួយខាងលើនេះក៏ត្រូវផ្តន្ទាទោសដូចការប្រព្រឹត្តបទល្មើសបានសម្រេចដែរ ។

## ផ្នែកទី ៣
## អ្នកសមគំនិត

### មាត្រា ៤៣.–

អ្នកសមគំនិតដោយដឹងហេតុផល ដែលផ្តល់មធ្យោបាយ ជួយទំនុកបំរុង ផ្តល់ជំនួយ ឬ ជួយណែនាំឱ្យប្រព្រឹត្តបទល្មើសណាមួយ ត្រូវផ្តន្ទាទោសដូចចារីនៃបទល្មើស ។

## ផ្នែកទី ៤
## កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ

### [១៥]មាត្រា ៤៤ ថ្មី.–

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុទាំងឡាយ ដែលធ្វើឡើងដោយចេតនាពាក់ព័ន្ធនឹងបទល្មើសដែលមានចែងក្នុងមាត្រា៣១ ថ្មី ដល់ មាត្រា ៣៨ ថ្មី នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទល្មើសនោះ ។

---

[១៤] មាត្រា ៤២ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[១៥] មាត្រា ៤៤ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

## ផ្នែកទី ៥

## បទប្បញ្ញត្តិដោយឡែក

### [១៦] មាត្រា ៤៥ ថ្មី.-

ទោសទាំងឡាយណាដែលមានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់ មាត្រា ៣៦ថ្មី និង មាត្រា ៣៧.២ថ្មី ដល់ មាត្រា ៤០ថ្មី នៃច្បាប់នេះ ត្រូវអនុវត្ត ទោះបីអំពើដែលជាធាតុផ្សំនៃបទល្មើសបានប្រព្រឹត្តនៅប្រទេសផ្សេងៗពីគ្នាក៏ដោយ ។

### មាត្រា ៤៦.-

នីតិបុគ្គលទាំងឡាយត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ អំពីអំពើល្មើសដែលមានចែងក្នុងច្បាប់នេះ តុលាការអាចផ្តន្ទាទោសណាមួយឬច្រើនមុខដូចតទៅ :

១- ពិន័យដែលមានទឹកប្រាក់អតិបរមាស្មើនឹង ៥ដង នៃអតិបរមានៃទោសដែលមានចែងក្នុងច្បាប់នេះ ។

២- រំលាយចោលនីតិបុគ្គលកាលណានីតិបុគ្គលនោះ បានបង្កើតឡើងក្នុងគោលបំណងបង្វែរកម្មវត្ថុរបស់នីតិបុគ្គលនោះ ដើម្បីប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥ ឆ្នាំ ។

៣- ហាមឃាត់ជាស្ថាពរឬសម្រាប់ចិរវេលា ៥ ឆ្នាំយ៉ាងយូរ មិនឱ្យប្រកបវិជ្ជាជីវៈឬធ្វើសកម្មភាពសង្គមណាមួយ ទោះបីដោយផ្ទាល់ឬដោយប្រយោល ។

៤- ដាក់ឱ្យស្ថិតនៅក្រោមការឃ្លាំមើលរបស់តុលាការ ក្នុងចិរវេលា ៥ឆ្នាំ យ៉ាងយូរ ។

៥- បិទទ្វារជាស្ថាពរឬសម្រាប់ចិរវេលា ៥ឆ្នាំយ៉ាងយូរ គ្រឹះស្ថានទាំងឡាយ ឬគ្រឹះស្ថានរបស់សហគ្រាសដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ។

៦- មិនឱ្យចូលរួមដេញថ្លៃជាសាធារណៈ ជាស្ថាពរឬសម្រាប់ចិរវេលា ៥ឆ្នាំយ៉ាងយូរ។

៧- ហាមឃាត់ជាស្ថាពរ ឬសម្រាប់ចិរវេលាមិនលើសពី ៥ ឆ្នាំ មិនឱ្យអំពាវនាវឱ្យសាធារណជនយកប្រាក់មកបើកគណនេយ្យសន្សំ ។

---

[១៦] មាត្រា ៤៥ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

៨- ហាមឃាត់សម្រាប់ចិរវេលា៥ឆ្នាំយ៉ាងយូរ មិនឱ្យចេញមូលប្បទានប័ត្រផ្សេងក្រៅពីមូលប្បទានប័ត្រសម្រាប់បេឡាឬមូលប្បទានប័ត្របញ្ជាក់ឬមិនឱ្យប្រើប្រាស់ប័ណ្ណសងប្រាក់។

៩- រឹបអូសតាមបញ្ញត្តិ ដែលមានចែងក្នុងមាត្រា ៥០ ដល់ មាត្រា ៥៩ ។

១០- បិទផ្សាយសេចក្តីសម្រេចរបស់តុលាការឬផ្សាយសេចក្តីសម្រេចនេះ តាមសារពត៌មានឬទូរទស្សន៍ ។

ទោសទី ១ ខាងលើនេះ មិនយកទៅអនុវត្តលើស្ថាប័នតំណាងបុគ្គលិកទេ ។

ទោសទី ១ និងទី ៣ ខាងលើ មិនយកទៅអនុវត្តលើនីតិបុគ្គលសាធារណៈ ដែលការទទួលខុសត្រូវអាចមានពាក់ព័ន្ធទេ ។

# ជំពូកទី ១២

## មូលហេតុទម្ងន់ទោស

### [១៧]មាត្រា ៤៧ ថ្មី.-

ត្រូវចាត់ទុកជាមូលហេតុទម្ងន់ទោសនូវករណីដូចមានខាងក្រោមនេះ :

១- កាលបើចារីនៃបទល្មើស ជាសមាជិករបស់ក្រុមចាត់តាំងជាខ្សែរយៈណាមួយ ។

២- កាលបើការប្រព្រឹត្តបទល្មើសគ្រឿងញៀន ជំរុញឱ្យចារីប្រព្រឹត្តបទល្មើសផ្សេងទៀត។

៣- កាលបើចារីនៃបទល្មើសបានប្រើហឹង្សា ឬអាវុធ ។

៤- កាលបើចារីនៃបទល្មើស ជាអ្នកបំពេញមុខងារសាធារណៈ ហើយបទល្មើសនោះបានប្រព្រឹត្តក្នុងពេលបំពេញមុខងារទាំងនោះ ។

៥- កាលបើបទល្មើស ត្រូវបានប្រព្រឹត្តដោយអ្នកប្រកបវិជ្ជាជីវៈ ខាងសុខាភិបាល ឬអ្នកដែលទទួលប្រយុទ្ធប្រឆាំងនឹងការប្រើ ឬការធ្វើជំនួញគ្រឿងញៀនខុសច្បាប់ ។

៦- កាលបើមានគ្រឿងញៀនផ្តល់ឱ្យ ឬស្នើឱ្យប្រើ ឬក៏មានការសម្រួលឱ្យប្រើគ្រឿងញៀនដល់អនីតិជន អ្នកវិកលចរិត ឬអ្នកដែលកំពុងទទួលការព្យាលបាលបន្សាបជាតិពុល ។

៧- កាលបើអនីតិជន ឬជនវិកលចរិតបានចូលរួមប្រព្រឹត្តបទល្មើស ។

[១៧] មាត្រា ៤៧ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

៨- កាលបើគ្រឿងញៀនដែលបានផ្តល់នោះបណ្តាលឱ្យជនណាម្នាក់ ឬច្រើន នាក់ស្លាប់ ឬទទួលផលវិបាកធ្ងន់ធ្ងរខាងសុខភាព ។

៩- កាលបើបទល្មើសប្រព្រឹត្តឡើងក្នុងគ្រឹះស្ថានពន្ធនាគារ គ្រឹះស្ថានយោធា គ្រឹះស្ថានសិក្សាអប់រំ មន្ទីរពេទ្យ ឬមន្ទីរព្យាបាលរោគ មជ្ឈមណ្ឌលសង្គមកិច្ច ឬនៅកន្លែងផ្សេងទៀតដែលមានសិស្ស និងនិស្សិតធ្វើសកម្មភាពអប់រំ កីឡា ឬសង្គមកិច្ច ឬមួយក៏បទល្មើសត្រូវបានប្រព្រឹត្តឡើងនៅជិតខាងជាប់នឹងគ្រឹះស្ថាន និងទីកន្លែងទាំងនោះ ។

១០- កាលបើចារីនៃបទល្មើសបន្ថែមក្នុងគ្រឿងញៀននូវសារធាតុផ្សេងទៀតដែលបណ្តាលឱ្យមានគ្រោះថ្នាក់រឹតតែធ្ងន់ធ្ងរទៀត ។

១១- កាលបើចារីនៃបទល្មើសស្ថិតក្នុងភាពមិនរាងចាល ការកាត់ទោសទាំងឡាយនៅឯបរទេស ត្រូវបានយកមកគិតបញ្ចូលជាភាពមិនរាងចាល ។

ប្រសិនបើការប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមបទល្មើស ដែលបានបញ្ញត្តិ ចាប់ពីមាត្រា ៣១ ថ្មី ដល់ មាត្រា ៤០ ថ្មី នៃច្បាប់នេះ ស្ថិតក្នុងករណីណាមួយដូចខាងលើ នោះត្រូវទម្ងន់ទោសតាមខ្នាតដូចខាងក្រោមនេះ ៖

ក- ប្រសិនបើអតិបរមានៃទោសជាប់ពន្ធនាគារក្រោម ឬស្មើ ២០ (ម្ភៃ) ឆ្នាំ អតិបរមានេះត្រូវទ្វេដង ។

ខ- ប្រសិនបើអតិបរមានៃទោសជាប់ពន្ធនាគារលើសពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

# ជំពូកទី ១៣
# ការលោះលាទោស ការសម្រាលទោស
# ចំពោះជនល្មើសក្រោយ

## ផ្នែកទី ១
## ការលោះលាទោស

### [១៨] មាត្រា ៤៨.- ថ្មី

ជនណាដែលមានពិរុទ្ធដោយការចូលរួមក្នុងក្រុមមួយ ឬ ក្នុងការព្រមព្រៀងគ្នាមួយ ដើម្បីប្រព្រឹត្តបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣១ ថ្មី ដល់មាត្រា ៤០ ថ្មី នៃច្បាប់នេះអាចត្រូវបានលោះលាពីទោស ប្រសិនបើពិរុទ្ធជននោះបានរាយការណ៍មុនពេលបទល្មើសកើតឡើង អំពីក្រុម ឬ ពីការព្រមព្រៀងគ្នានេះ ជូនអាជ្ញាធររដ្ឋបាល ឬតុលាការឱ្យមានពេលវេលាគ្រប់គ្រាន់ ដើម្បីបញ្ចៀសបាននូវការសម្រេចបទល្មើស ឬ ស្គាល់ជនដទៃទៀតដែលពាក់ព័ន្ធ និងបញ្ចៀសបាន នូវការសម្រេចបទល្មើស និងសង្កេត ឬ អង្កេតសកម្មភាពល្មើសច្បាប់របស់ក្រុមនេះ ។

## ផ្នែកទី ២
## ការសម្រាលទោស

### [១៩] មាត្រា ៤៩.- ថ្មី

ក្រៅពីករណីដែលមានចែងក្នុងមាត្រាខាងលើនេះ ត្រូវបានសម្រាលទោសពាក់កណ្ដាលនៃអតិបរមានៃទោសដែលមានចែងក្នុងមាត្រា៣១ ថ្មី ដល់មាត្រា ៤០ ថ្មី នៃច្បាប់នេះ ដល់ចារីឬអ្នកសមគំនិត ដែលបានរាយការណ៍ឱ្យស្គាល់ពិរុទ្ធជនដទៃទៀត មុនពេលដែលខ្លួនត្រូវបានចោទប្រកាន់ឬដែលបានជួយសម្រួលឱ្យចាប់ពិរុទ្ធជនបាន ក្រោយពេលដែលខ្លួនត្រូវបានចោទប្រកាន់ ។

[១៨] មាត្រា ៤៨ ( និរាករណ៍ដោយច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[១៩] មាត្រា ៤៩ ( និរាករណ៍ដោយច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ម្យ៉ាងទៀត ជននោះត្រូវបានឱ្យរួចខ្លួនន្ធូវការពិន័យ ព្រមទាំងពីអនុទោស និងពីទោសបន្ថែមឥតកំហិតទាំងឡាយ ។

## ជំពូកទី ១៤
## ទោស និងវិធានការបន្ទាប់បន្សំ ឬបំពេញបន្ថែម

### ផ្នែកទី ១
### ការរឹបអូសវិធានការរក្សាទុកជាបណ្ដោះអាសន្នសម្រាប់ធានាការរឹបអូស

**មាត្រា ៥០.-**

ក្នុងករណីមានការចោទប្រកាន់ វិធានការរក្សាទុកទ្រព្យសម្បត្តិនិងវត្ថុទាំងឡាយដែលជារបស់ជនជាប់ចោទ ឬបានមកពីបទល្មើសឬត្រូវសង្ស័យថាបានប្រើប្រាស់ឬបំរុងទុកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ត្រូវចាត់ឡើងតាមល័ក្ខខ័ណ្ឌដែលកំណត់ក្នុងច្បាប់ ។

### ផ្នែកទី ២
### ការរឹបអូសខានមិនបាន

[២០] **មាត្រា ៥១ ថ្មី.-**

តុលាការដែលសម្រេចសេចក្ដីផ្ដន្ទាទោស ឬដោះលែង ឬលើកលែងចោទប្រកាន់អំពីបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣១ ថ្មី ដល់ មាត្រា ៣៨.១ ថ្មី និងមាត្រា៩៨ ថ្មី បញ្ជាឱ្យរឹបអូសគ្រឿងញៀនដែលចាប់បាន ហើយមិនទាន់កំទេចចោល ឬមិនទាន់បញ្ជូនទៅគ្រឹះស្ថានណាមួយ ឬទៅបុគ្គលណាម្នាក់ដែលត្រូវបានអនុញ្ញាតឱ្យរក្សាទុក ។

កាលបើមិនបានធ្វើបណ្ដឹងអាជ្ញាទេ ការរឹបអូសដែលមានចែងនៅកថាខណ្ឌខាងលើ ត្រូវសម្រេចដោយប្រធានតុលាការ តាមសេចក្ដីសន្និដ្ឋានរបស់អយ្យការ ។

---

[២០] មាត្រា ៥១ (និរាករណ៍ដោយច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

## [២១] មាត្រា ៥២ ថ្មី.-

ក្នុងករណីផ្តន្ទាទោសលើបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣១ថ្មី ដល់មាត្រា៣៩ថ្មី និងមាត្រា ៩៨ថ្មី តុលាការដែលបានកាត់សេចក្តី ត្រូវបញ្ជាឱ្យរឹបអូសឧបករណ៍ សម្ភារៈ សារធាតុ សម្រាប់ផលិតគ្រឿងញៀន និងវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ ឬទុកបំរុងប្រើប្រាស់សម្រាប់ប្រព្រឹត្ត បទល្មើស ។

ក្នុងករណីផ្តន្ទាទោសលើបទល្មើសដែលមានចែងក្នុងមាត្រា ៣៩ ថ្មី តុលាការដែលបាន កាត់សេចក្តី ត្រូវបញ្ជាឱ្យរឹបអូសធនធាន ឬទ្រព្យសម្បត្តិជាកម្មវត្ថុនៃបទល្មើស ព្រមទាំងប្រតិលាភ ទាំងឡាយនិងអត្ថប្រយោជន៍ផ្សេងទៀត ដែលកើតចេញពីធនធាន និងទ្រព្យសម្បត្តិទាំងនោះ ។

## [២២] មាត្រា ៥៣ ថ្មី.-

ក្នុងករណីផ្តន្ទាទោសលើបទល្មើសណាមួយ ដែលបានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់ មាត្រា ៣៦ ថ្មី និងមាត្រា ៣៧.២ ថ្មី ដល់ មាត្រា ៣៩ ថ្មី នៃច្បាប់នេះ តុលាការដែល បានកាត់សេចក្តី ត្រូវបញ្ជាឱ្យរឹបអូសធនធាន និងទ្រព្យសម្បត្តិគ្រប់ប្រភេទដែលបានមកពី បទល្មើស ហើយដែលចូលជាមរតករបស់ជនជាប់ទោសក្នុងរយៈពេល ៥ ឆ្នាំ មុនពេលផ្តន្ទាទោស លើកលែងតែជននោះបានបង្ហាញភស្តុតាងជាក់ស្តែងថា ធនធាន ឬទ្រព្យសម្បត្តិទាំងនោះមិនមែន បានមកដោយផ្ទាល់ ឬដោយប្រយោលពីបទល្មើសទេ ។

ត្រូវចាត់ទុកជាបានមកពីបទល្មើស ទ្រព្យសម្បត្តិជាចលនវត្ថុ ឬអចលនវត្ថុ ដែលបានមកពី ការបំប្លែង ឬការវិនិយោគផលដែលបានមកពីបទល្មើស ។

ការរឹបអូសធនធាន ឬទ្រព្យសម្បត្តិបើកសិទ្ធិពេញច្បាប់ឱ្យរឹបអូសប្រតិលាភ ឬអត្ថប្រយោជន៍ ដទៃទៀត ដែលកើតមកពីធនធាន ឬទ្រព្យសម្បត្តិនោះ ។

---

[២១] មាត្រា ៥២ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[២២] មាត្រា ៥៣ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

កាលបើផលដែលបានមកពីបទល្មើស ត្រូវបានលាយឡំនៅក្នុងទ្រព្យសម្បត្តិបានមកដោយស្របច្បាប់ ការរឹបអូសទ្រព្យសម្បត្តិនោះ អាចធ្វើទៅបានតែក្នុងកំរិតតម្លៃនៃផលដែលមានលាយឡំក្នុងទ្រព្យសម្បត្តិស្របច្បាប់នោះ ហើយដែលតុលាការបានប៉ាន់ប្រមាណ ។

សេចក្តីសម្រេចឱ្យរឹបអូស ត្រូវចង្អុលបញ្ជាក់ទ្រព្យសម្បត្តិដែលត្រូវរឹបអូសឱ្យច្បាស់ ដើម្បីងាយស្រួលស្គាល់ និងស្រួលរកឃើញ ។

## [២៣]មាត្រា ៥៤ ថ្មី.-

ក្នុងករណីមានការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៣៤ ថ្មី តុលាការត្រូវបញ្ជាឱ្យរឹបអូសទ្រព្យសម្បត្តិចលនវត្ថុ ឬអចលនវត្ថុរបស់អង្គការឧក្រិដ្ឋណាមួយដែលខ្លួនត្រួតពិនិត្យផ្ទាល់ និងបានប្រើប្រាស់ ។

ត្រូវចាត់ទុកជាអង្គការឧក្រិដ្ឋ ក្រុមជនទុច្ចរិត ដែលបានបង្កើតឡើងក្នុងគោលបំណង និងមានកម្មវត្ថុប្រព្រឹត្តម្តងហើយម្តងទៀតដោយផ្ទាល់ ឬ ក្រោមរូបភាពនៃសកម្មភាពស្របច្បាប់ នូវបទល្មើសដែលចែងក្នុងមាត្រា ៣១ ថ្មី ដល់មាត្រា៤០ ថ្មី នៃច្បាប់នេះ ឬសកម្មភាពឧក្រិដ្ឋផ្សេងទៀត ។

## ផ្នែកទី ៣

## ការរឹបអូសឥតកំហិត

## [២៤]មាត្រា ៥៥ ថ្មី.-

ក្នុងករណីមានការផ្តន្ទាទោសតាមបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣៥.១ ថ្មី និងចំណុច ក នៃកថាខណ្ឌទី១ មាត្រា៣៥.២ថ្មី តុលាការអាចចេញបញ្ជាឱ្យរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ និងចលនវត្ថុ ដែលមានក្នុងទីកន្លែងប្រព្រឹត្តបទល្មើស ។

---

[២៣] មាត្រា ៥៤ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។
[២៤] មាត្រា ៥៥ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

## ផ្នែកទី ៤
## ការអនុវត្តនៃការរឹបអូស

### មាត្រា ៥៦.-

ការលក់ទ្រព្យរឹបអូស ត្រូវធ្វើដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមទំរង់បែបបទសម្រាប់លក់ទ្រព្យសម្បត្តិរបស់រដ្ឋ ។

ទ្រព្យទាំងឡាយដែលបានមករដ្ឋ តាមការរឹបអូស នៅជាបន្ទុកស្មើនឹងតម្លៃនៃទ្រព្យនោះ សម្រាប់សងបំណុលស្របច្បាប់ដែលមានមុនពេលតុលាការរឹបអូស ឬមុនពេលប្រគល់ទ្រព្យនោះឱ្យអ្នកថែរក្សាទុក ឬមុនពេលចាត់វិធានការផ្សេងទៀតសម្រាប់ថែរក្សាទុក ។

វិធានការត្រឹមត្រូវសម្រាប់រាប់រងការអនុវត្តន៍បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៥៧.-

មូលនិធិទាំងឡាយដែលបានមកពីការរឹបអូស និងប្រាក់ដែលបានមកពីការលក់ ឬប្រាក់ដែលនៅសល់ក្រោយពីបានសងម្ចាស់បំណុលរួចអស់ហើយ ត្រូវដាក់ចូលទៅក្នុងបេឡាមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលស្ថិតនៅក្រោមអំណាចរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

អាជ្ញាធរជាតិនេះ ចាត់ចែងប្រាក់នៅសល់ក្នុងបេឡាផ្តល់ឱ្យអង្គការរដ្ឋ ឬឱ្យទៅសមាគមឯកជនដែលមានការធានាខាងមុខជំនាញប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ ឬការធ្វើជំនួញគ្រឿងញៀនខុសច្បាប់ និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

ល័ក្ខខ័ណ្ឌនៃការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី ៥
## ការបដិសេធអំពើទាំងឡាយដែលប៉ុនប៉ងបង្កើត
## ឧបសគ្គដល់ការរឹបអូស

### [២៥] មាត្រា ៥៨ ថ្មី.-

ត្រូវទុកជាមោឃៈគ្រប់សារលិខិតដែលធ្វើឡើងដោយបង់កម្រៃក្តី ឬគ្មានបង់កម្រៃក្តីជាមរតកសាសន៍ ឬជាសារលិខិតធ្វើឡើងរវាងមនុស្សនៅមានជីវិត ទោះបីដោយផ្ទាល់ ឬតាមរយៈតតិយជន ឬតាមអ្នកបញ្ជូនមកដោយប្រយោល ហើយដែលមានទិសដៅបង្វេះទ្រព្យទាំងឡាយឱ្យផុតពីវិធានការរឹបអូស ។ លើកលែងតែមានភស្តុតាងផ្ទុយ រាល់ទង្វើចាត់ចែង ឬគ្រប់គ្រងត្រូវចាត់ទុកជាបានធ្វើឡើងក្នុងទិសដៅបង្វេះទ្រព្យសម្បត្តិ បើទង្វើនោះត្រូវបានបំពេញតាំងពីពេលចាប់ខ្លួន ឬចោទប្រកាន់ពីបទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា៣១ ថ្មី ដល់ មាត្រា៤០ ថ្មី លើម្ចាស់ទ្រព្យ ដែលមានការពាក់ព័ន្ធ ឬលើបុគ្គលដែលម្ចាស់ទ្រព្យបច្ចុប្បន្នបានទទួលទ្រព្យនោះមក ។

តុលាការរដ្ឋប្បវេណីមានសមត្ថកិច្ចកាត់សេចក្តីលុបចោលសារលិខិត ។ ប្រសិនបើតុលាការសម្រេចលុបចោលកិច្ចសន្យាលក់ តម្លៃប្រាក់លក់ត្រូវប្រគល់ទៅឱ្យអ្នកទិញវិញ ប្រសិនបើមានភស្តុតាងថា អ្នកទិញបានបង់ថ្លៃនោះរួចហើយ ។

## ផ្នែកទី ៦
## ការបង្ក្រាបឧបសគ្គនៃការរឹបអូស

### [២៦] មាត្រា ៥៩ ថ្មី.-

ជនណាដែលដឹងហេតុការណ៍ហើយ ហើយបានជួយសម្រួលឬប៉ុនប៉ងជួយសម្រួលការលួចដកយកបរិក្ខារ សម្ភារៈ សារធាតុសម្រាប់ផលិតគ្រឿងញៀន ឬវត្ថុអ្វីផ្សេងទៀត ធនធាន និង

---

[២៥] មាត្រា ៥៨ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[២៦] មាត្រា ៥៩ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ទ្រព្យសម្បត្តិ ដែលត្រូវបញ្ជាឱ្យរឹបអូសតាមបទប្បញ្ញត្តិនៃមាត្រា៥១ ថ្មី ដល់ មាត្រា ៥៤ ថ្មី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ដោយពុំទាន់គិតដល់ទោសចែងអំពីបទល្មើសសមគំនិតក្នុងបទល្មើសដែលគ្រោងទុកក្នុងមាត្រា ៣១ ថ្មី ដល់មាត្រា៤០ ថ្មី នៃច្បាប់នេះ បើសិនជាមាន ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ១០.០០០.០០០(ដប់លាន)រៀល។

## ជំពូកទី ១៥
## ទោសឥតកំហិត

### [២៧]មាត្រា ៦០ ថ្មី.-

១- ក្នុងករណីទាំងឡាយដែលមានចែងក្នុងជំពូកទី ១០ ជំពូកទី ១១ និងជំពូកទី១២ ព្រមទាំងមាត្រា ៩៣ មាត្រា ៩៧ និង មាត្រា ៩៨ ថ្មី តុលាការ អាចសម្រេចបន្ថែមទៀត :

ក- ហាមឃាត់មិនឱ្យចូលមក ឬរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់ចិរវេលាពី ១ (មួយ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ ចំពោះជនបរទេស ។

ខ- ហាមឃាត់ការស្នាក់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ចិរវេលាពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ចំពោះជនបរទេស ។

គ- ដកសិទ្ធិពលរដ្ឋសម្រាប់ចិរវេលាពី ១ (មួយ) ឆ្នាំទៅ ៥ (ប្រាំ)ឆ្នាំ ប៉ុន្តែចិរវេលានេះមិនត្រូវលើសពីចិរវេលាផ្តន្ទាទោសឡើយ ។

ឃ- មិនឱ្យចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងដកហូតលិខិតឆ្លងដែនសម្រាប់ចិរវេលាពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ង- ហាមឃាត់ការបើកបរយានយន្តគ្រប់ប្រភេទ និងដកហូតលិខិតបើកបរ សម្រាប់ចិរវេលាពី ១ (មួយ) ខែ ទៅ ៣ (បី) ឆ្នាំ ។

ច- ហាមឃាត់ជាស្ថាពរ ឬសម្រាប់ចិរវេលាពី១ (មួយ)ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ មិនឱ្យប្រកបអាជីព ដែលមានសាមីខ្លួនបានប្រព្រឹត្តល្មើសក្នុងពេលប្រកបអាជីពនោះ។

---

[២៧] មាត្រា ៦០ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

២- ក្នុងករណីទាំងឡាយដែលមានចែងក្នុងមាត្រា ៣២.១ថ្មី ដល់៣៦ថ្មី និង មាត្រា ៣៧.២ ថ្មី ដល់ មាត្រា៤០ ថ្មី នៃច្បាប់នេះ តុលាការអាចសម្រេចឱ្យ ៖

ក- បិទទ្វារសម្រាប់ថិរវេលាពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ កន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្តឡើងដោយអាជីវករ ឬដោយការសមគំនិតរបស់អាជីវករ ជាអាទិ៍ ចំពោះសណ្ឋាគារ ផ្ទះឈ្នួលមានចលនវត្ថុប្រើប្រាស់ស្រាប់ កន្លែងទទួលឱ្យនៅ និងបរិភោគ តៀមលក់ភេសជ្ជៈ ភោជនីយដ្ឋាន សមាគមកំសាន្ត កន្លែងរាំច្រៀង និងកន្លែងទស្សនីយភាព ឬសាខារបស់ទីតាំងនោះ ឬកន្លែងធ្វើអ្វីមួយ បើកសម្រាប់សាធារណជន ឬប្រើប្រាស់ដោយសាធារណជន ។

ខ- ដកហូតលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពី ១(មួយ) ឆ្នាំដល់៥(ប្រាំ) ឆ្នាំ ។

## [២៨]មាត្រា ៦១ ថ្មី.-

ជនណាដែលប្រព្រឹត្តល្មើសនឹងការហាមឃាត់ទាំងឡាយ ដែលមានចែងក្នុងមាត្រា ៦០ ថ្មី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ដោយពុំទាន់គិតដល់បទប្បញ្ញត្តិដែលផ្តន្ទាទោសធ្ងន់ជាងនេះ ប្រសិនបើត្រូវធ្វើ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

# ជំពូកទី ១៦

# វិធានការបំពេញបន្ថែម

## [២៩]មាត្រា ៦២ ថ្មី.-

កាលបើជនញៀនគ្រឿងញៀន ត្រូវផ្តន្ទាទោសដោយបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣១ថ្មី ដល់ មាត្រា ៤០ថ្មី នៃច្បាប់នេះ តុលាការអាចចាត់បន្ថែមលើទោសនូវវិធានការព្យាបាលដែលមានចែងក្នុងផ្នែកទី ២ នៃជំពូកទី ២៤ ។

---

[២៨] មាត្រា ៦១ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[២៩] មាត្រា ៦២ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

# ជំពូកទី ១៧
# បទប្បញ្ញត្តិពិសេសនៃនីតិវិធី

## ផ្នែកទី ១
## សមត្ថកិច្ច

**មាត្រា ៦៣.-**

តុលាការនៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចសម្រេចសេចក្តីលើបទល្មើសទាំងឡាយៈ

-កាលបើបទល្មើសបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬកាលបើអំពើណាមួយដែលជាធាតុផ្សំនៃបទល្មើសបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

-កាលបើបទល្មើសបានប្រព្រឹត្តឡើងដោយប្រជាពលរដ្ឋខ្មែរ ឬដោយបុគ្គលណាដែលរស់នៅជាប្រក្រតីលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

-កាលបើចារីស្ថិតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយចារីនោះពុំទាន់បានបញ្ជូនខ្លួនទៅឱ្យប្រទេសដើមនៅឡើយ ។

-កាលបើជនល្មើសបានប្រព្រឹត្តនៅលើអាកាសយាន ដែលបានចុះបញ្ជីនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឬនៅលើនាវាដែលបង្គូតទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

-លើកលែងតែមានកិច្ចព្រមព្រៀងនិងកិច្ចសម្រុះសម្រួលរវាងរដ្ឋ កាលបើបទល្មើស បានប្រព្រឹត្តនៅក្នុងនាវា ដែលរដ្ឋជាម្ចាស់ទង់ជាតិ បានអនុញ្ញាតិឱ្យព្រះរាជាណាចក្រកម្ពុជា បញ្ជាឱ្យឈប់ ដើម្បីឆែកពិនិត្យមើល និងចាត់វិធានការសមស្របចំពោះនាវាចំពោះមនុស្សដែលនៅក្នុងនាវានិងចំពោះនាវាភ័ណ្ឌ ក្នុងករណីដែលរកឃើញមានភស្តុតាងថា មានការចូលរួមក្នុងការធ្វើជំនួញគ្រឿងញៀនខុសច្បាប់ ។

## ផ្នែកទី ២
## អាជ្ញាយុកាល

### [៣០]មាត្រា ៦៤ ថ្មី.-

បទល្មើសដែលមានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់ មាត្រា ៣៤ ថ្មី និង មាត្រា ៣៩ថ្មី ដែលអតិបរមានៃទោសលើសពី៥(ប្រាំ)ឆ្នាំ ត្រូវផុតអាជ្ញាយុកាល ១៥ (ដប់ប្រាំ) ឆ្នាំ ។

ទោសដែលត្រូវផ្តន្ទាចំពោះបទល្មើសណាមួយខាងលើ ដែលអតិបរមានៃទោស លើសពី ៥ (ប្រាំ) ឆ្នាំ ត្រូវផុតអាជ្ញាយុកាល ២០(ម្ភៃ) ឆ្នាំ គិតពីថ្ងៃដែលសាលក្រម ឬសាលដីកាស្ថាពរ ។

អាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោសឯទៀត ត្រូវអនុវត្តតាមនីតិសាមញ្ញ ។

## ផ្នែកទី ៣
## ការឃាត់ទុក

### មាត្រា ៦៥.-

ក្នុងករណីមានបទល្មើសដូចមានចែងក្នុងជំពូកទី ១០ និងទី ១១ គ្រឿងញៀន និងសារធាតុសម្រាប់ផលិតគ្រឿងញៀនត្រូវឃាត់ទុកជាបន្ទាន់។ត្រូវឃាត់ទុកជាបន្ទាន់ដែរនូវឋបនភ័ណ្ឌ សម្ភារៈបរិក្ខានិងទ្រព្យជាចលនវត្ថុផ្សេងទៀតដែលសង្ស័យថាត្រូវបានប្រើប្រាស់ឬសម្រាប់ប្រើប្រាស់ ដើម្បីប្រព្រឹត្តបទល្មើសទាំងអស់នេះ ប្រាក់និងតម្លៃចលនវត្ថុដែលសង្ស័យថា បានមកពីបទល្មើស ដោយផ្ទាល់ឬដោយប្រយោលព្រមទាំងឯកសារទាំងអស់ ដែលមានលក្ខណៈសម្រួលដល់ការបង្ហាញភស្តុតាងនៃបទល្មើសនិងពិរុទ្ធភាពនៃចារី ដោយមិនអាចលើកយកមកសម្អាងថាជាឯកសារសម្ងាត់ក្នុងវិជ្ជាជីវៈបានឡើយ ។

---

[៣០] មាត្រា ៦៤ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

# ជំពូកទី ១៨
# បទប្បញ្ញត្តិសម្រាប់សម្រួលការស៊ើបអង្កេត

## ផ្នែកទី ១
## ការឃាត់ខ្លួន

### [៣១]មាត្រា ៦៦ ថ្មី.~

ក្នុងករណីទាំងឡាយដែលមានចែងក្នុងមាត្រា៣២.១ ថ្មី ដល់មាត្រា ៣៤ ថ្មី និងមាត្រា ៣៩ថ្មី នៃច្បាប់នេះ រយៈពេលនៃការឃាត់ខ្លួនគឺ ៤៨ ម៉ោងយ៉ាងយូរ ។

ចាប់តាំងពីដំបូងនៃការឃាត់ខ្លួន បើជនត្រូវឃាត់ខ្លួនបានសុំព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ បើរឿងនោះបានទៅដល់ខ្លួនហើយ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ត្រូវចាត់គ្រូពេទ្យឱ្យពិនិត្យជនឃាត់ខ្លួន ២៤ម៉ោងម្តងៗ។ គ្រូពេទ្យ ត្រូវចេញលិខិតបញ្ជាក់ដោយបង្ហាញហេតុផលក្រោយពីបានពិនិត្យម្តងៗ លិខិតនេះត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។ ការពិនិត្យផ្សេងទៀត ត្រូវតែធ្វើ បើសិនជាជនឃាត់ខ្លួនមានសំណូមពរ ។

លិខិតបញ្ជាក់សុខភាពបញ្ជាក់ជាពិសេសថា តើជនឃាត់ខ្លួននោះជាអ្នកញៀនគ្រឿងញៀន ឬទេ? ហើយថា តើសុខភាពរបស់ជននោះអាចឱ្យជននោះនៅក្នុងទីឃុំឃាំងបានឬទេ ?

ការចំណាយថ្លៃពេទ្យត្រូវជាបន្ទុករបស់ជនឃាត់ខ្លួន ។ បើជនឃាត់ខ្លួននោះជាជនក្រីក្រ ការចំណាយថ្លៃពេទ្យ ត្រូវជាបន្ទុករបស់រដ្ឋ ។

---

[៣១] មាត្រា ៦៦ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

## ផ្នែកទី ២
## ការឆែកឆេរ

### [៣២]មាត្រា ៦៧ ថ្មី.-

ការទៅពិនិត្យមើល ការឆែកឆេរ និងការឃាត់ទុកក្នុងទីកន្លែងដែលគេផលិត បំប្លែង ឬតម្កល់ទុកដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ គ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ឬសារធាតុសម្រាប់ផលិតគ្រឿងញៀន បរិក្ខារ និងសម្ភារៈ សម្រាប់ដាំរុក្ខជាតិញៀន សម្រាប់ផលិតដោយខុសច្បាប់នូវគ្រឿងញៀនទាំងនោះ និងនៅក្នុងទីកន្លែងដែលគេប្រើរួមគ្នាច្រើននូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ អាចប្រព្រឹត្តទៅបានគ្រប់ពេលវេលាទាំងថ្ងៃ ទាំងយប់ ។

ការទៅពិនិត្យមើល ការឆែកឆេរ និងការឃាត់ទុកអាចធ្វើបានក្នុងពេលយប់ តែក្នុងករណីស្រាវជ្រាវ និងពិនិត្យកត់ត្រាបទល្មើសដែលមានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់ មាត្រា ៣៥.២ ថ្មី មាត្រា ៣៨.១ ថ្មី និង មាត្រា ៣៨.២ ថ្មី នៃច្បាប់នេះប៉ុណ្ណោះ ។

គ្រប់កំណត់ហេតុដែលធ្វើសម្រាប់កម្មវត្ថុផ្សេងពីករណីនេះត្រូវទុកជាមោឃៈ ។

ការទៅពិនិត្យមើលការឆែកឆេរខាងលើនេះ ត្រូវមានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា ឬពីចៅក្រមស៊ើបសួរ កាលបើរឿងនោះបានទៅដល់ចៅក្រមស៊ើបសួរហើយ ។

## ផ្នែកទី ៣
## ការត្រួតពិនិត្យក្នុងសេវាប្រៃសណីយ៍

### [៣៣]មាត្រា ៦៨ ថ្មី.-

[៣២] មាត្រា ៦៧ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។
[៣៣] មាត្រា ៦៨ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

បុគ្គលដែលមាននីតិសម្បទាពិនិត្យកត់ត្រាឬបង្ក្រាបបទល្មើសទាំងឡាយ ដែលមានចែងក្នុងមាត្រា ៣១ ថ្មី ដល់ ៤៦ នៃច្បាប់នេះ ត្រូវបានអនុញ្ញាតិឱ្យតាមដានគ្រប់ពេលម៉ោង ទាំងថ្ងៃទាំងយប់នូវសេវាប្រៃសណីយ៍ ដើម្បីរុករកការផ្ញើបញ្ជូនខុសច្បាប់នូវគ្រឿងញៀន និងសារធាតុសម្រាប់ផលិតគ្រឿងញៀន ។

កាលបើមានសញ្ញាធ្ងន់ធ្ងរល្មមនាំឱ្យសន្មតបានថា មានការផ្ញើបញ្ជូនបែបនេះ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ប្រសិនបើរឿងនេះបានទៅដល់ខ្លួនហើយ អាចតម្រូវឱ្យមន្ទីរប្រៃសណីយ៍ស្រាយបើកកញ្ចប់ដែលផ្ញើបញ្ជូននោះបាន ។

## ផ្នែកទី ៤

## ការឆែករុករក

### [៣៤] មាត្រា ៦៩ ថ្មី.-

បុគ្គលដែលមាននីតិសម្បទាពិនិត្យកត់ត្រា ឬបង្ក្រាបបទល្មើសដែលមានចែងក្នុងមាត្រា៣១ ថ្មី ដល់មាត្រា៤៦ នៃច្បាប់នេះ ត្រូវបានអនុញ្ញាតឱ្យឆែកឆេរនៅព្រំដែនលើខ្លួនបុគ្គល យានជំនិះ ឬឥវ៉ាន់ បង្វិច ហឹប កាលបើមានសញ្ញានាំឱ្យសង្ស័យថា មានការប្រព្រឹត្តបទល្មើសដែលមានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់ មាត្រា ៣៤ ថ្មី និង មាត្រា ៩៨ ថ្មី ។ ការឆែកខ្លួនបុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នាតាមបទបញ្ញាជាធរមាន។

## ផ្នែកទី ៥

## ការតាមដានដោយផ្អែកលើបច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រ

### [៣៥] មាត្រា ៧០ ថ្មី.-

កាលបើមានសញ្ញាធ្ងន់ធ្ងរល្មមឱ្យសន្មតថា ជនណាម្នាក់ដែលឆ្លងព្រំដែនមាននាំមកនូវគ្រឿងញៀន លាក់ក្នុងសរីរាង្គកាយ អ្នករាជការដែលមាននីតិសម្បទាពិនិត្យកត់ត្រាបទល្មើស អាចដាក់ជននោះឱ្យគ្រូពេទ្យ ឬអ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រ ពិនិត្យ តាមដាន ជាអាទិ៍ ដោយប្រើ

---

[៣៤] មាត្រា ៦៩ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[៣៥] មាត្រា ៧០ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

បច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រ ក្រោយពីបានទទួលការយល់ព្រមដោយលាយលក្ខណ៍អក្សរពីសាមីខ្លួន ។ ក្នុងករណីសាមីខ្លួនមិនយល់ព្រម អ្នករាជការនោះ ត្រូវប្ដឹងសុំការអនុញ្ញាតពីព្រះរាជអាជ្ញា។ បណ្ដឹងនោះអាចបញ្ជូនតាមគ្រប់មធ្យោបាយ។ ព្រះរាជអាជ្ញាដែលទទួលបណ្ដឹងអាចអនុញ្ញាតឱ្យធ្វើការពិនិត្យតាមវេជ្ជសាស្ត្រ ។ ព្រះរាជអាជ្ញាចាត់តាំងគ្រូពេទ្យ ឬអ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រឱ្យធ្វើការពិនិត្យជាបន្ទាន់ ។ លទ្ធផលនៃការពិនិត្យ ដែលគ្រូពេទ្យផ្ដល់ឱ្យការមានយោបល់ជនដែលមានការពាក់ព័ន្ធនឹងកិច្ចដំណើរការនៃការពិនិត្យ ត្រូវចុះកំណត់ហេតុដែលត្រូវធ្វើជូនទៅព្រះរាជអាជ្ញា ។

ជនណាប្រកែកមិនព្រមឱ្យត្រួតពិនិត្យតាមអាជ្ញាបញ្ជារបស់ព្រះរាជអាជ្ញា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែដល់ ១ (មួយ)ឆ្នាំ ឬផ្ដន្ទាទោសពិន័យជាប្រាក់ពី២០០.០០០ (ពីរសែន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល ។

## ផ្នែកទី ៦
## ការប្រគល់ដោយមានការឃ្លាំមើលរូបិយប័ណ្ណ ឧបករណ៍ ដែលមានបច្ច័យដល់រូបិយវត្ថុ

### [៣៦] មាត្រា ៧១ ថ្មី.-

ការឆ្លងកាត់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជានូវរុក្ខជាតិ ឬសារធាតុ រូបិយប័ណ្ណ ឧបករណ៍ដែលមានបច្ច័យដល់រូបិយវត្ថុ ដែលមានចែងក្នុងច្បាប់នេះ ដែលធ្វើបញ្ជូនដោយខុសច្បាប់ ឬសង្ស័យថាខុសច្បាប់ ហើយដែលអាជ្ញាធរមានសមត្ថកិច្ច ដឹងឮ ហើយតាមដាន ដើម្បីពិនិត្យកត់ត្រាបទល្មើសទាំងឡាយ ដែលមានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់ មាត្រា ៣៣ ថ្មី មាត្រា ៣៧.២ ថ្មី ដល់ មាត្រា ៣៧.៤ ថ្មី មាត្រា ៣៨.១ ថ្មី និង មាត្រា ៣៨.២ ថ្មី អាចអនុញ្ញាតឱ្យឆ្លងកាត់បានដើម្បីតាមដានរកអត្តសញ្ញាណជនទាំងឡាយ ដែលជាប់ពាក់ព័ន្ធក្នុងបទល្មើសនោះ ដើម្បីធ្វើការចោទប្រកាន់ ។

---

[៣៦] មាត្រា ៧១ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ការអនុញ្ញាតឱ្យធ្វើក្នុងគោលដៅដូចខាងលើនេះដែរ ការញុះញង់អ្នករាជការមានសមត្ថកិច្ច ដើម្បីពិនិត្យកត់ត្រាបទល្មើសឱ្យលក់ដោយខុសច្បាប់នូវរុក្ខជាតិនិងសារធាតុទាំងឡាយ ទោះបីដោយផ្ទាល់ ឬតាមរយៈជនណាម្នាក់ ដែលប្រព្រឹត្តតាមការណែនាំរបស់អ្នករាជការនោះ ។

ការញុះញង់ឱ្យទិញដោយខុសច្បាប់នូវរុក្ខជាតិ និងសារធាតុដែលប្រព្រឹត្តដោយអ្នករាជការមានសមត្ថកិច្ច ដើម្បីពិនិត្យកត់ត្រាបទល្មើសទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ត្រូវហាមឃាត់ បើពុំនោះទេ នឹងត្រូវចោទប្រកាន់ពីបទល្មើសញុះញង់ ដែលមានចែងក្នុងមាត្រា ៤១ ថ្មី និងទុកការអង្កេតជាមោឃៈ ទោះបីអ្នករាជការនោះប្រព្រឹត្តដោយផ្ទាល់ ឬតាមរយៈជនណាម្នាក់ក៏ដោយ ។

## មាត្រា ៧២.-

ការសម្រេចឱ្យប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ឬប្រើវិធីឱ្យលក់ដោយខុសច្បាប់ ត្រូវធ្វើដោយអាជ្ញាធរដែលចាត់តាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬដោយមន្ត្រីប្រតិភូដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចាត់តាំងសម្រេចករណីនីមួយៗហើយបើសិនជាត្រូវធ្វើ គឺផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងជាមួយប្រទេសឯទៀតដែលមានប្រយោជន៍ក្នុងរឿងនេះ។ សេចក្តីសម្រេចឱ្យប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ត្រូវជូនដំណឹងភ្លាមទៅតុលាការមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងបញ្ជូនចេញឬកន្លែងបញ្ជូនចូលមកលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានេះ ម្យ៉ាងម្យ៉ាងទៀតត្រូវជូនដំណឹងភ្លាមផងដែរ ទៅតុលាការមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងដែលប្រគល់ឬកន្លែងបញ្ចេញ ។

សេចក្តីសម្រេចអនុញ្ញាតិឱ្យប្រើវិធីញុះញង់ឱ្យលក់ដោយខុសច្បាប់ ត្រូវជូនដំណឹងភ្លាមទៅតុលាការមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងលក់ ។

## មាត្រា ៧៣.-

អាជ្ញាធរចាត់តាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រតិភូរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដឹកនាំនិងត្រួតពិនិត្យកិច្ចប្រតិបត្តិការលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបញ្ជាឱ្យធ្វើអន្តរាគមន៍ ដែលមន្ត្រីនោះយល់ឃើញថាជាការសមស្រប ។ បើមានការព្រមព្រៀងពីប្រទេសឯទៀតដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬដោយអនុលោមជាយថាហេតុទៅលើកិច្ចព្រមព្រៀង

ខាងហិរញ្ញវត្ថុ អាជ្ញាធរ ឬប្រតិភូនោះអាចសម្រេចឱ្យចាំស្កាត់ចាប់វត្ថុបញ្ជូនខុសច្បាប់ ដែលអាចអនុញ្ញាតឱ្យបញ្ជូនបន្តដូចដើម ឬឱ្យបញ្ជូនបន្តក្រោយពីឃាត់ទុករូបិយប័ណ្ណ ឧបករណ៍ ដែលមានបច្ច័យដល់រូបិយវត្ថុ រុក្ខជាតិ ឬសារធាតុហើយដាក់ផលិតផលផ្សេងជំនួសវិញ ។

## ផ្នែកទី ៧

## ការឃ្លាំមើល

### មាត្រា ៧៤.-

ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរប្រសិនបើរឿងនេះបានទៅដល់ខ្លួនហើយ អាច :

១- ដាក់ក្រោមការឃ្លាំមើលនូវគណនីធនាគារ និងគណនីឯទៀតដែលចាត់ទុកដូចជាគណនីធនាគារ

២- ដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់

៣- ចូលទៅពិនិត្យប្រព័ន្ធកុំព្យូទ័រ

៤- សុំឱ្យផ្តល់លិខិតយថាភូតឬលិខិតឯកជន និងឯកសារធនាគារហិរញ្ញវត្ថុ និងពាណិជ្ជកម្មទាំងអស់។ កាលបើមានសញ្ញាធ្ងន់ល្មមឱ្យឃើញថាគណនី ខ្សែទូរស័ព្ទ ឬប្រព័ន្ធកុំព្យូទ័រទាំងនោះ ត្រូវបានប្រើប្រាស់ ឬអាចយកទៅប្រើប្រាស់ដោយបណ្តាជនដែលសង្ស័យថាប្រព្រឹត្ត ឬបានប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងជំពូកទី ១០ និង ទី ១១ ឬកាលបើលិខិត ឬឯកសារទាំងនោះពាក់ព័ន្ធ ឬអាចនឹងពាក់ព័ន្ធទៅនឹងបទល្មើសណាមួយខាងលើនេះ ។

វិធានការខាងលើនេះ មិនអាចចាត់ទុកជាការរំលោភលើការសម្ងាត់ខាងវិជ្ជាជីវៈបានឡើយ។

ការដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់ អាចអនុញ្ញាតិបានតែក្នុងចិរវេលាក្រោម ២ខែ ។ ការបន្តវិធានការនេះ ត្រូវបានអនុញ្ញាតិតែដោយចៅក្រមស៊ើបអង្កេតដែលកាន់រឿងនេះ។

### [៣៧] មាត្រា ៧៥ ថ្មី.-

[៣៧] មាត្រា ៧៥ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ដោយមិនទាន់គិតដល់ទោសទាំងឡាយ ដែលផ្តន្ទាចំពោះបទល្មើសដែលមានចែងក្នុងជំពូកទី១០ និង ១១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ចំពោះ :

ក- ជនណាដែលបានដឹងដោយសារការប្រកបវិជ្ជាជីវៈរបស់ខ្លួន អំពីការចាត់វិធានការណាមួយដែលមានចែងក្នុងមាត្រា ៧៤ ខាងលើ ហើយបានប្រាប់ដោយចេតនាដល់បណ្តាជនដែលមានការពាក់ព័ន្ធ ។

ខ- ជនណាដែលផ្តល់ទៅតុលាការ ទៅអ្នករាជការមានសមត្ថកិច្ចនូវលិខិត ឬឯកសារដែលមានចែងក្នុងចំណុច៤ នៃមាត្រា ៧៤ ខាងលើនេះ ដែលខ្លួនបានដឹងថាជាឯកសារដែលមានគេដកចេញខ្លះ ឬជាឯកសារក្លែងបន្លំ ប៉ុន្តែមិនបាន ជម្រាបអាជ្ញាធរទាំងនោះឱ្យបានដឹង ។

ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

## ផ្នែកទី ៨

## ការហាមឃាត់មិនឱ្យសម្អាងលើអាថ៌កំបាំងធនាគារដើម្បីប្រកែក

## មិនផ្តល់ភស្តុតាងឬចម្លើយជាសាក្សី

### មាត្រា ៧៦.-

អាថ៌កំបាំងខាងធនាគារពុំអាចត្រូវបានលើកយកមកជាសម្អាង ដើម្បីប្រកែកមិនព្រមផ្តល់ភស្តុតាងឬចម្លើយជាសាក្សីលើហេតុការណ៍ទាំងឡាយ ដែលអាចជាបទល្មើសណាមួយដែលមានចែងក្នុងជំពូកទី ១០ និង ១១ ។

# ជំពូកទី ១៩

# ការមិនទូទាត់សងបំណុលឱ្យទាន់ពេល

### [៣៨] មាត្រា ៧៧ ថ្មី.-

---

[៣៨] មាត្រា ៧៧ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥) ។

ក្នុងករណីមានការចោទប្រកាន់ពីបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣២.១ ថ្មី ដល់មាត្រា ៣៥.២ ថ្មី ត្រង់ចំណុច ក និងចំណុច ង នៃកថាខណ្ឌ ទី១ មាត្រា ៣៧.២ ថ្មី ដល់ មាត្រា ៣៨.២ ថ្មី តុលាការ ឬចៅក្រមស៊ើបសួរ អាចបញ្ជាឱ្យបិទទ្វារជាបណ្ដោះអាសន្ន សម្រាប់ចិរវេលា ៦ (ប្រាំមួយ) ខែ យ៉ាងយូរ ចំពោះ សណ្ឋាគារ ផ្ទះឈ្នួល មានចលនវត្ថុប្រើប្រាស់ស្រាប់ កន្លែងទទួលភ្ញៀវឱ្យនៅ និងបរិភោគ តៀមភេសជ្ជៈ ភោជនីយដ្ឋាន ក្លឹប សមាគមកំសាន្ត កន្លែងរាំច្រៀង កន្លែងទស្សនីយភាព ឬសាខាកន្លែងនោះ ឬកន្លែងណាមួយ ដែលបើកឱ្យសាធារណជន ឬប្រើប្រាស់ដោយសាធារណជន ហើយដែលនៅទីនោះមានកើតបទល្មើសប្រព្រឹត្តដោយអាជីវករ ដោយសារការសមគំនិតរបស់អាជីវករ ។

ការបិទទ្វារនេះអាចបន្តឱ្យធ្វើតាមរូបភាពដដែលសម្រាប់ចិរវេលា ៦(ប្រាំមួយ)ខែយ៉ាងយូរ។

សេចក្ដីសម្រេចទាំងឡាយ ដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវយកទៅអនុវត្តភ្លាម ទោះបីមានបណ្ដឹងឧទ្ធរណ៍ក៏ដោយ ។

## ជំពូកទី ២០
## ការឱ្យចូលរួមក្នុងនីតិវិធីនៃរឿង

**មាត្រា ៧៨.-**

ជនជាប់ចោទទាំងឡាយពីបទល្មើសណាមួយ ដែលមានចែងក្នុងជំពូកទី ១០ និងទី១១ ហើយស្ថិតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្ខំតាមគ្រប់មធ្យោបាយស្របច្បាប់ឱ្យចូលរួមក្នុងនីតិវិធីព្រហ្មទណ្ឌដែលពាក់ព័ន្ធដល់ខ្លួន ។

# ជំពូកទី ២១
# បទប្បញ្ញត្តិស្តីអំពីការអនុវត្តទោស

## ផ្នែកទី ១
## ការហាមឃាត់មិនឱ្យរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា

### [៣៩] មាត្រា ៧៩ ថ្មី.-

ការហាមឃាត់មិនឱ្យរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្រេចលើជនបរទេសណាមួយ ដោយអនុវត្តតាមចំនុច (ក) កថាខណ្ឌទី ១ នៃមាត្រា ៦០ ថ្មី នាំទៅដល់ការបណ្តេញទណ្ឌិតចេញពីប្រទេស ក្រោយពីបានរងទោសពន្ធនាគាររួចហើយ ។

ក្នុងករណីហាមឃាត់ជាស្ថាពរមិនឱ្យរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វិធានការនេះ មិនអាចលុបចោលនៅថ្ងៃក្រោយបានឡើយ ។

## ផ្នែកទី ២
## ការដាក់ពន្ធនាគារបង្ខំដល់រូបកាយ

### [៤០] មាត្រា ៨០ ថ្មី.-

ចិរវេលានៃការដាក់ពន្ធនាគារបង្ខំដល់រូបកាយ មានកំណត់ ២ (ពីរ)ឆ្នាំ កាលបើប្រាក់ពិន័យ និងធនទ័ណ្ឌ សម្រេចលើបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា៣១ ថ្មីដល់៤០ថ្មី ឬសម្រេចលើបទល្មើសគយ ដែលមានការពាក់ព័ន្ធមានចំនួនលើសពី១០.០០០.០០០៖០០(ដប់លាន)រៀល។

---

[៣៩] មាត្រា ៧៩ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[៤០] មាត្រា ៨០ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

## ផ្នែកទី ៣
## ការត្រួតទោស

### [៤១]មាត្រា ៨១ ថ្មី.-

កាលបើនៅក្នុងនីតិវិធីតែមួយ ជនជាប់ចោទត្រូវបានសម្រេចថា មានពិរុទ្ធពីបទល្មើសច្រើនបទ ក្នុងនោះ មានបទល្មើសណាមួយចូលក្នុងចំណោមបទល្មើសដែលមានចែងក្នុងមាត្រា ៣១ ថ្មី ដល់មាត្រា ៤០ ថ្មី ជននោះត្រូវទទួលរងគ្រប់ទោសទាំងអស់ដែលបានសម្រេច ហើយទោសពន្ធនាគារត្រូវអនុវត្តត្រួតគ្នាក្នុងកម្រិតមិនឱ្យលើសពីអតិបរមានៃទោសដែលខ្ពស់បំផុត ។

កាលបើនៅក្នុងនីតិវិធីដាច់ពីគ្នា ជនជាប់ចោទត្រូវបានផ្តន្ទាទោសពីបទល្មើសច្រើនបទ ក្នុងនោះ មានបទល្មើសណាមួយចូលក្នុងចំណោមបទល្មើសដែលរៀបរាប់ខាងលើ ហើយបើហេតុការណ៍ដែលបានបណ្តាលឱ្យផ្តន្ទាទោសណាមួយបានប្រព្រឹត្តឡើង មុនការផ្តន្ទាទោសមួយទៀតចូលជាស្ថាពរ ជននោះត្រូវទទួលគ្រប់ទោសទាំងអស់ដែលបានសម្រេច ហើយទោសដាក់ពន្ធនាគារ ត្រូវអនុវត្តត្រួតគ្នាក្នុងកំរិតមិនឱ្យលើសពីអតិបរមានៃទោសដែលខ្ពស់បំផុត ។

# ជំពូកទី ២២
# បទប្បញ្ញត្តិស្តីពីការរក្សាទុកឬការបំផ្លាញចោលនូវវត្ថុតាងនិងសារធាតុដែលបានឃាត់ទុក

## ផ្នែកទី ១
## ការធ្វើនិងល័ក្ខខ័ណ្ឌនៃការរក្សាទុកត្រាអាចចំល័ក្ខ

### មាត្រា ៨២.-

[៤១] មាត្រា ៨១ (និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ក្នុងគ្រប់ករណីទាំងអស់ដែលមានចែងក្នុងជំពូកទី ១០ និង ១១ និង ក្នុងមាត្រា ៩៨ និង ៩៩ ថ្នាំញៀន សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទនិងសារធាតុសម្រាប់ផលិតគ្រឿងញៀនត្រូវឃាត់ទុក ហើយដាក់ក្នុងកញ្ចប់ ប្រអប់ ឬហឹបបិទត្រាអាចម៍ល័ក្ខ តាំងពីពេលរកឃើញ ។

កញ្ចប់ ប្រអប់ ឬហឹប បិទត្រាអាចម៍ល័ក្ខ ត្រូវធ្វើយ៉ាងណាឱ្យការពារបាន កុំឱ្យមានការលួចដកហូតរុក្ខជាតិឬសារធាតុក្នុងនោះ ។

កញ្ចប់បិទត្រាអាចម៍ល័ក្ខនិមួយៗត្រូវដាក់លេខរៀង និងមានសរសេរពីលើសំបកកញ្ចប់ ឬសរសេរលើស្លាកបិទត្រាអាចម៍ល័ក្ខ រាយសេចក្តីអំពីប្រភេទ និងទម្ងន់រុក្ខជាតិ និងសារធាតុដែលនៅក្នុងនោះ ព្រមទាំងចំនួនកញ្ចប់ដែលមានរុក្ខជាតិឬសារធាតុដែលមានក្នុងនោះ ។ កំណត់ហេតុមួយត្រូវធ្វើភ្លាមបញ្ជាក់ ថ្ងៃ ខែ ឆ្នាំ ទីកន្លែងកាលៈទេសៈនៃការរកឃើញ បញ្ជាក់ពីរុក្ខជាតិនិងសារធាតុដែលឃាត់ទុក បញ្ជាក់ទម្ងន់ និងវិធីថ្លឹងដែលបានប្រើ និងបញ្ជាក់ពីតេស្ត និងលទ្ធផលនៃតេស្តនោះប្រសិនបើបានធ្វើ ។ កំណត់ហេតុនោះបញ្ជាក់ផងដែរ នូវចំនួនកញ្ចប់បិទត្រាអាចម៍ល័ក្ខ និងរាយសេចក្តីដូចមានចែងខាងលើឡើងវិញ ។

កំណត់ហេតុបញ្ជាក់ទីកន្លែងដែលយកកញ្ចប់ប្រអប់ ឬហឹបបិទត្រាអាចម៍ល័ក្ខទៅតម្កល់ទុក ព្រមទាំងកំណត់សំគាល់ផ្សេងទៀតដែលមានប្រយោជន៍ ។

កំណត់ហេតុនិងកំណត់សរសេរលើកញ្ចប់ ប្រអប់ ឬហឹបនិមួយៗត្រូវចុះហត្ថលេខា ដោយអ្នកដែលបានចូលរួមរៀបចំធ្វើកញ្ចប់ទាំងអស់នោះ ។

កញ្ចប់ ប្រអប់ ឬហឹប បិទត្រាអាចម៍ល័ក្ខ ត្រូវរក្សាទុកក្នុងល័ក្ខខ័ណ្ឌសមស្រប ដើម្បីការពារកុំឱ្យមានការលួចឬកែបន្លំបាន ។ ការយកកញ្ចប់ ប្រអប់ ឬហឹប បិទត្រាអាចម៍ល័ក្ខទៅណាមកណាក្រោយមកទៀត ត្រូវធ្វើកំណត់ហេតុមួយកត់ត្រាបញ្ជាក់ពីទីកន្លែងដែលយកទៅដាក់ និងកម្មវត្ថុនៃចលនានោះ ។

កំណត់ហេតុនេះកត់ត្រាថាឬមួយត្រាអាចម៉ីល័ក្ខនិងកញ្ចប់ទាំងអស់នៅល្អគង់វង្ស ហើយថាចំនួនមានត្រឹមត្រូវតាមចំនួនក្នុងកំណត់ហេតុឃាត់ទុក ឬថាមានការបាត់បង់ ឬមានការខូចខាតត្រាអាចម៍ល័ក្ខនិងមានការប្រែភាពដើម ។

## ផ្នែកទី ២

## ការដកយកជាសំណាក

### មាត្រា ៨៣.-

អាជ្ញាធរតុលាការមានសមត្ថកិច្ចដកយកជាបន្ទាន់នូវសំណាកយ៉ាងតិចបីកញ្ចប់ ឬតាមចំនួនដែលត្រូវការជាចាំបាច់នៅចំពោះមុខជនពាក់ព័ន្ធក្នុងបទល្មើស ឬបើគ្មានអ្នកពាក់ព័ន្ធនៅចំពោះមុខសាក្សីពីរនាក់ ដើម្បីធ្វើជាភស្តុតាងនិងជាការកត់សម្គាល់ភិនភាគនៃរុក្ខជាតិ ឬសារធាតុដែលឃាត់ទុក ។ សំណាកនិមួយៗត្រូវដាក់ក្នុងកញ្ចប់បិទត្រាអាចម៍ល័ក្ខ ។ លើកញ្ចប់ លើស្លាក ភ្ជាប់និងត្រាអាចម៍ល័ក្ខ ត្រូវមានកត់ចំណាំប្រភេទនិងទម្ងន់នៃវត្ថុនៅខាងក្នុង ។ បន្ទាប់ពីការដកយកសំណាកហើយ ត្រូវបិទត្រាអាចម៍ល័ក្ខឡើងវិញលើកញ្ចប់ដើម ហើយត្រូវធ្វើកំណត់ហេតុមួយបញ្ជាក់ចំនួនសំណាក ដែលបានដកយកប្រភេទ និងទម្ងន់នៃរុក្ខជាតិនិងសារធាតុ ដែលមានក្នុងកញ្ចប់និមួយៗ ព្រមទាំងការផ្លាស់ប្តូរទៅលើត្រាអាចម៍ល័ក្ខដើម ។ កំណត់ហេតុនិងការសរសេរបញ្ជាក់ទាំងអស់លើសំណាកនីមួយៗ និងលើត្រាអាចម៍ល័ក្ខដែលបិទឡើងវិញ ត្រូវចុះហត្ថលេខាដោយជនទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រតិបត្តិការដកសំណាក ។

## ផ្នែកទី ៣

## កោសលវិច័យ

### មាត្រា ៨៤.-

កោសលវិច័យដោយអ្នកជំនាញដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ដើម្បីឱ្យបានដឹងអំពីប្រភេទធាតុផ្សំនិងកំរិតធាតុសកម្មរបស់រុក្ខជាតិ និងសារធាតុដែលឃាត់ទុក ត្រូវធ្វើដោយឆាប់បំផុតបន្ទាប់ពីការឃាត់ទុក ដើម្បីចៀសវាងការខូចខាតថយចុះនូវសារធាតុរូបវត្ថុនិងជាតិគីមីនៃវត្ថុនោះ ។ អ្នកជំនាញត្រូវបញ្ជាក់ក្នុងរបាយការណ៍របស់ខ្លួននូវចំនួនសំណាកដែលគេបានប្រគល់ឱ្យអំពីប្រភេទ និងទម្ងន់នៃរុក្ខជាតិនិងសារធាតុដែលមាននៅក្នុងសំណាកនិមួយៗ ចំនួនសំណាកដែលបានប្រើ ប្រាស់ធ្វើកោសលវិច័យ

ហើយប្រសិនបើមាន ត្រូវបញ្ជាក់ចំនួនសំណាកដែលប្រមូលមកវិញសល់ពីការធ្វើកោសលវិច័យនិងការប្រែប្រួលទៅលើសំណាកទាំងនោះ ។

## ផ្នែកទី ៤
## ការប្រគល់និងការបំផ្លាញចោលនូវសារធាតុទាំងឡាយដែលបានឃាត់ទុក

### [៤២] មាត្រា ៨៥ ថ្មី.-

លើកលែងតែក្នុងករណីដែលការរក្សាទុករុក្ខជាតិ និងសារធាតុឃាត់ទុកជាការចាំបាច់ដាច់ខាតសម្រាប់ដំណើរការនីតិវិធី អាជ្ញាធរខាងតុលាការក្រោយពីបានឃាត់ទុក ឬក្រោយពីដកយកសំណាក ត្រូវបញ្ជា និងចាត់ការឱ្យអនុវត្តជាបន្ទាន់នូវ :

ក- ការប្រគល់ឱសថដែលអាចប្រើប្រាស់បានឱ្យទៅក្រសួងសុខាភិបាល ។

ខ- ការប្រគល់រុក្ខជាតិ និងសារធាតុ ដែលអាចប្រើប្រាស់ក្នុងឧស្សាហកម្ម ឱសថ ឬប្រើផ្សេងទៀតឱ្យទៅក្រសួងសុខាភិបាល។

គ- ការបំផ្លាញចោលទាំងស្រុងនូវរុក្ខជាតិនិងសារធាតុផ្សេងទៀត ដែលត្រូវធ្វើភ្លាមៗនិងតាមមធ្យោបាយសមស្របបំផុត នៅចំពោះមុខគណៈកម្មការ ដែលត្រូវបង្កើតឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ក្នុងករណីដែលការរក្សាទុករុក្ខជាតិ និងសារធាតុជាការចាំបាច់សម្រាប់ដំណើរការនីតិវិធី ការប្រគល់ ឬការបំផ្លាញចោល ត្រូវធ្វើយ៉ាងឆាប់បំផុត ក្រោយពេលដែលសេចក្ដីសម្រេចរឹបអូសត្រូវចូលជាស្ថាពរ ។

ការប្រគល់ និងការបំផ្លាញចោល ត្រូវពិនិត្យកត់ត្រាក្នុងកំណត់ហេតុមួយ ដែលមានបញ្ជាក់ច្បាស់លាស់អំពីអាចម៍ល័ក្ខដែលត្រូវបានប្រគល់ ឬបំផ្លាញចោល ។

---

[៤២] មាត្រា ៨៥ ( និរាករណ៍ដោយច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ស្លាកនៃត្រាអាចម៉ល័ក្ខ ឬចំណារនៅលើកញ្ចប់ ត្រូវដាក់ជាឧបសម្ព័ន្ធភ្ជាប់ជាមួយកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយបុគ្គលទាំងអស់ ដែលបានចូលរួមក្នុងការប្រគល់ ឬការបំផ្លាញចោលនោះ ។

ក្នុងករណីបម្រើឱ្យកិច្ចការស្រាវជ្រាវ ស៊ើបអង្កេត ស្ថាប័នមានសមត្ថកិច្ចមានសិទ្ធិស្នើសុំរក្សាទុករុក្ខជាតិ ឬសារធាតុទាំងឡាយក្នុងកម្រិតសមស្របនឹងតម្រូវការ ។ ស្ថាប័នតុលាការមានសិទ្ធិសម្រេចក្រោយពេលមានការស្នើសុំ ។

# ជំពូកទី ២៣
# ការផ្តល់ទៅអនីតិជននូវជាតិគីមីពុលសម្រាប់ហិតស្រូប

## [៤៣]មាត្រា ៨៦ ថ្មី.-

១- ជនដែលដឹងច្បាស់ហេតុផល ហើយនៅតែផ្តល់ឱ្យអនីតិជន ហិតស្រូប នូវជាតិគីមីពុលណាមួយ ដែលមានចុះក្នុងបញ្ជីកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ក- ប្រព្រឹត្តបទល្មើសច្រើនដង ។

ខ- ចំពោះជនរងគ្រោះច្រើននាក់ ។

គ- បណ្តាលឱ្យមានជម្ងឺគ្រោះថ្នាក់ធ្ងន់ធ្ងរ។

[៤៣] មាត្រា ៨៦ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

## ជំពូកទី ២៤
## វិធានការប្រឆាំងនិងការប្រើប្រាស់គ្រឿងញៀនដោយបំពាន

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ៨៧.-

ការប្រើគ្រឿងញៀនដោយបំពាននិងការប្រើប្រាស់ខុសច្បាប់នូវគ្រឿងញៀនមានន័យថា ការប្រើគ្រឿងញៀនហាមឃាត់ និងការប្រើប្រាស់ក្រៅបញ្ជារបស់គ្រូពេទ្យនូវគ្រឿងញៀនឯទៀតៗដែរ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

អ្នកញៀនជាតិពុល គឺជនដែលចំណុះគ្រឿងញៀន ទាំងរូបកាយ ទាំងស្មារតី បានន័យថា មិនអាចអត់បាននូវគ្រឿងញៀនដែលស្ថិតក្រោមការត្រួតពិនិត្យនៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។

ការព្យាបាលបន្សាបជាតិពុល គឺការព្យាបាលបំបាត់ការចំណុះរូបកាយទៅនឹងគ្រឿងញៀន។

### មាត្រា ៨៨.-

ការប្រើប្រាស់គ្រឿងញៀនហាមឃាត់ និងការប្រើប្រាស់ក្រៅពីវេជ្ជបញ្ជានូវគ្រឿងញៀនឯទៀតៗដែលស្ថិតនៅក្រោមការត្រួតពិនិត្យ ត្រូវហាមឃាត់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

## ផ្នែកទី ២
## វិធានការព្យាបាល

## [៤៤] មាត្រា ៨៩ ថ្មី.-

អ្នកញៀនជាតិពុល ដែលចូលទៅសុំព្យាបាលដោយខ្លួនឯងនៅក្នុងមន្ទីរពេទ្យ ឬអង្គការឯកទេសណាមួយ ត្រូវបានទទួលរក្សាការសម្ងាត់ពីអង្គការ ឬស្ថាប័នទាំងនោះ បើសាមីខ្លួនសុំយ៉ាងនេះ ។ ចំណាយលើការព្យាបាលក្នុងមន្ទីរពេទ្យ ឬអង្គការឯកទេស ឬគិលានដ្ឋានរបស់រដ្ឋត្រូវជាបន្ទុកទាំងស្រុងរបស់រដ្ឋ ។

ជនដែលទទួលការព្យាបាលក្នុងល័ក្ខខ័ណ្ឌដូចដែលបានចែងនៅកថាខណ្ឌទី១ អាចសុំឱ្យមន្ទីរពេទ្យ ឬអង្គការដែលព្យាបាល ចេញលិខិតបញ្ជាក់ឈ្មោះខ្លួន ថ្ងៃ ខែ ឆ្នាំ រយៈពេល និងកម្មវត្ថុនៃការព្យាបាល ។

មន្ត្រីដែលអនុវត្តវិធានការព្យាបាល និងស្តារនីតិសម្បទា មិនត្រូវទទួលការចោទប្រកាន់ចំពោះសកម្មភាពដែលខ្លួនបានធ្វើក្នុងវង្វង់សិទ្ធិស្របតាមវិធីសាស្ត្រព្យាបាល និងស្តារនីតិសម្បទាសម្រាប់អ្នកញៀនគ្រឿងញៀនឡើយ ។

## [៤៥] មាត្រា ៩០ ថ្មី.-

ការចោទប្រកាន់មិនត្រូវធ្វើលើជនណាដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ៩៨ថ្មី កថាខ័ណ្ឌទី២ ហើយបានចូលខ្លួនដោយខ្លួនឯងទៅទទួលការព្យាបាលមុនការចោទប្រកាន់។

## [៤៦] មាត្រា ៩១ ថ្មី.-

ព្រះរាជអាជ្ញាអាចកោះហៅជនដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៨ ថ្មី កថាខណ្ឌទី២ ឱ្យចូលទៅបង្ហាញខ្លួនចំពោះមុខតុលាការក្នុងរយៈពេលមិនតិច ជាង ១(មួយ) ខែ ហើយក៏មិនលើស ពី ៦(ប្រាំមួយ) ខែ ហើយអាចបង្គាប់ឱ្យ ចូលខ្លួនក្នុងរយៈពេល ៨(ប្រាំបី) ថ្ងៃ ទៅក្នុងគ្រឹះស្ថានព្យាបាលណាមួយដែលបានចែងក្នុងមាត្រា៨៩ ថ្មី ដើម្បីទទួលការព្យាបាលសមស្របតាមសុខភាពរបស់ខ្លួន។ ព្រះរាជអាជ្ញា ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួនទៅគ្រឹះស្ថានព្យាបាលនោះ ។

---

[៤៤] មាត្រា ៨៩ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[៤៥] មាត្រា ៩០ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

[៤៦] មាត្រា ៩១ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

បើជននោះមិនចូលខ្លួនទៅគ្រឹះស្ថានព្យាបាលទេ ឬក៏គេចវេះពីការព្យាបាលដែលគ្រឹះស្ថាននោះកំណត់ឱ្យធ្វើ តុលាការត្រូវយកបទប្បញ្ញត្តិនៃមាត្រា ៩៤ ថ្មី ទៅអនុវត្តលើជននោះ ។

បើជននោះបានទទួលការព្យាបាលតាមបង្គាប់រហូតដល់ទីបញ្ចប់ ឬបើជននោះបានបន្តការព្យាបាលដោយទៀងទាត់ តុលាការអាចប្រកាសថាមិនដាក់ទោស ។

## មាត្រា ៩២.-

ជនដែលត្រូវជាប់ចោទពីបទល្មើសដែលមានចែងក្នុងមាត្រា ៩៨ បើពិនិត្យទៅឃើញថាជននោះញៀនជាតិពុល តុលាការអាចសម្រេចបង្ខំឱ្យជននោះ ទៅទទួលវិធានការព្យាបាល សមស្របនឹងសុខភាពរបស់ខ្លួន ក្នុងរយៈពេលអនុវត្តនីតិវិធី ។

បើជននោះទទួលការព្យាបាលរហូតដល់ទីបញ្ចប់ តុលាការ អាចសម្រេចត្រឹមតែធ្វើការព្រមានប៉ុណ្ណោះ ។

## មាត្រា ៩៣.-

អ្នកញៀនជាតិពុលដែលត្រូវបានផ្តន្ទាទោសពីបទល្មើស ដែលមានចែងក្នុងមាត្រា៩៨ កថាខណ្ឌទី ២ អាចសុំដោយស្ម័គ្រចិត្តចូលទៅព្យាបាលតាមសភាពនៃសុខភាពរបស់ខ្លួនបាន ក្រោយពីការកាត់ទោស ។ ក្នុងករណីនេះការអនុវត្តន៍ទោសត្រូវផ្អាកសិន ។ សាមីជនដែលបានទទួលការព្យាបាលរហូតដល់ចប់ ត្រូវចាត់ទុកថាបានទទួលរងទោសរួចហើយ ។

ទោសនោះ ត្រូវយកមកអនុវត្តវិញភ្លាម កាលបើទណ្ឌិតមិនព្រមទទួលការព្យាបាល ឬមិនព្រមទទួលការព្យាបាលរហូតដល់ចប់ ។

## [៤៧] មាត្រា ៩៤ ថ្មី.-

ជនណាគេចវេះពីវិធានការព្យាបាលដែលមានចែងក្នុងមាត្រា ៩១ ថ្មី មាត្រា ៩៥ មាត្រា ៩៦ និងមាត្រា ៩៧ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ដល់ ១ (មួយ) ខែ

[៤៧] មាត្រា ៩៤ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ឬផ្តន្ទាទោសពិន័យជាប្រាក់ពី ២៥.០០០ (ពីរម៉ឺនប្រាំពាន់) រៀលដល់ ១០០.០០០ (មួយសែន) រៀល ។

## មាត្រា ៩៥.-

តុលាការផ្នែករដ្ឋប្បវេណីដែលបានទទួលបណ្តឹងពីសហព័ទ្ធ ឬពីឪពុកម្តាយ ឬសាច់ញាតិរបស់សាមីជន ឬពីអយ្យការប្តឹងទៅតុលាការរដ្ឋប្បវេណីថា សាមីជនដែលជាអ្នកញៀនជាតិពុលជាមនុស្សដែលគេស្គាល់ថាមានគ្រោះថ្នាក់ដល់អ្នកដទៃនោះ តុលាការរដ្ឋប្បវេណីអាចបង្ខំសាមីជននោះ ឱ្យស្ថិតនៅព្យាបាលក្នុងមន្ទីរពេទ្យឬអង្គការឯកទេសណាមួយ ដែលមានចែងក្នុងមាត្រា៨៩ ។

## មាត្រា ៩៦.-

កាលបើអ្នកញៀនជាតិពុលប្រព្រឹត្តបទល្មើស ដែលមិនធ្ងន់ល្មមនឹងផ្តន្ទាទោសដាក់ពន្ធនាគារ ហើយបើជននោះមិនដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយព្យួរទោស ឬមិនព្យួរទោសក្នុងរយៈពេល៣ឆ្នាំកន្លងទៅទេ នោះតុលាការអាចសម្រេចមិនដាក់ទោសប៉ុន្តែត្រូវបង្ខំជននោះឱ្យទៅទទួលការព្យាបាល ។

## មាត្រា ៩៧.-

អ្នកញៀនជាតិពុល ដែលតុលាការផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៦ ខែ ដោយព្យួរទោសពីបទល្មើសផ្សេងទៀត នោះតុលាការ អាចបង្ខំឱ្យជននោះទទួលវិធានការព្យាបាល ។

## ផ្នែកទី ៣

## វិធានការបង្ក្រាប

## [៤៨]មាត្រា ៩៨ ថ្មី.-

[៤៨] មាត្រា ៩៨ ( និវាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ដោយពុំទាន់គិតដល់បទប្បញ្ញត្តិនៃមាត្រា ៣១ ថ្មី ដល់ មាត្រា ៣៧.៦ ថ្មី ជនណាប្រព្រឹត្តខុសច្បាប់ដោយរក្សាទុក ទិញ ឬដាំដុះ ដោយចេតនាសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួននូវរុក្ខជាតិ ឬសារធាតុដែលចាត់ទុកជាថ្នាំញៀន ឬសារធាតុ ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ដល់ ១ (មួយ) ខែ ។

ជនណាប្រើប្រាស់ដោយខុសច្បាប់នូវរុក្ខជាតិ ឬសារធាតុដែលចាត់ទុកជាថ្នាំញៀន ឬសារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ដល់ ១ (មួយ) ខែ ។

ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ ពី ២៥.០០០(ពីរម៉ឺនប្រាំពាន់) រៀលដល់ ១០០.០០០(មួយសែន)រៀល ។

ក្នុងករណីមិនរាងចាល ឬប្រសិនបើអ្នកប្រព្រឹត្តបទល្មើសជាអ្នកមានមុខរបរខាងគ្រប់គ្រង និងព្យាបាលសុខភាព ទោសខាងលើនេះត្រូវទ្វេដង។

ក៏ប៉ុន្តែប្រសិនបើក្នុងកាលៈទេសៈនៃមូលហេតុដែលបទល្មើសណាមួយ ដូចបានចែងខាងលើ បានប្រព្រឹត្តដោយមានបរិមាណបន្តិចបន្តួច និងប្រព្រឹត្តក្នុងក្របខ័ណ្ឌទទួលទានតាមទម្លាប់ ព្រះរាជអាជ្ញា អាចឱ្យជនប្រព្រឹត្តរួចខ្លួនពីបទចោទ។ ប្រសិនបើរឿងនេះទៅដល់តុលាការ ប្រធានតុលាការ អាចសម្រេចឱ្យចារីនៃហេតុការណ៍នេះ មិនបាច់ទទួលទោសឬគ្រាន់តែព្រមានជននោះតែប៉ុណ្ណោះ។ ត្រូវចាត់ទុកថាជាការទទួលទានតាមទម្លាប់ ការទទួលទានដែលមិនបណ្តាលឱ្យញៀន ហើយអ្នកទទួលទាន ជាអ្នកស្រុក ទទួលទានតាមដូនតា ធ្លាប់ប្រព្រឹត្តជាយូរមកហើយ ។

## [៤៩] មាត្រា ៩៩ ថ្មី.-

១- ជនណាដែលបើកបរយានយន្ត តាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស នៅពេលដែលខ្លួនស្ថិតនៅក្រោមឥទ្ធិពលនៃថ្នាំមានសារជាតិញៀនដែលខ្លួនបានប្រើដោយខុសច្បាប់ និងបណ្តាលឱ្យមានគ្រោះថ្នាក់ ទោះបីគ្មានសញ្ញាបង្ហាញឱ្យឃើញពីខាងក្រៅថាខ្លួនញៀនក៏ដោយ ត្រូវផ្តន្ទាទោស

[៤៩] មាត្រា ៩៩ ( និរាករណ៍ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ) ។

ដាក់ពន្ធនាគារពី ១(មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២០០.០០០(ពីរសែន)រៀលដល់ ២.០០០.០០០ (ពីរលាន)រៀល ។

២- ករណីបង្កឱ្យមានអន្តរាយធ្ងន់ធ្ងរដល់រូបកាយ សុខភាព ឬគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាយុជីវិតអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំដល់ ៣ (បី) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចទទួលបន្ថែមនូវទោសពិន័យជាប្រាក់ ពី ២.០០០.០០០ (ពីរលាន)រៀល ដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល។

៣- ជនណាប្រកែកមិនព្រមដាក់ខ្លួនឱ្យគេធ្វើតេស្តពិនិត្យគ្រឿងញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ថ្ងៃ ដល់ ១ (មួយ) ខែ ឬផ្តន្ទាទោសពិន័យជាប្រាក់ពី ២៥.០០០ (ពីរម៉ឺនប្រាំពាន់)រៀលដល់ ១០០.០០០(មួយសែន)រៀល ។

# ជំពូកទី ២៥

# កិច្ចសហប្រតិបត្តិការអន្តរជាតិ

## ផ្នែកទី ១

## បទប្បញ្ញត្តិរួមស្តីពីបត្យាប័ននិងការជួយគ្នាទៅវិញទៅមកខាងតុលាការ

### មាត្រា ១០០.-

ក្នុងករណីគ្មានសន្ធិសញ្ញា បត្យាប័ន និងការជួយគ្នាទៅវិញទៅមកខាងតុលាការចំពោះបទល្មើសដែលមានចែងក្នុងជំពូកទី ១០ និង ១១ ត្រូវអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃជំពូកទី ២៥ ដែលអនុវត្តបានផងដែរ ទៅលើចំណុចដែលមិនបានបញ្ញត្តិដោយសន្ធិសញ្ញា ។

### មាត្រា ១០១.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមិនចាត់ទុកបទល្មើសទាំងឡាយ ដែលមានចែងក្នុងមាត្រាខាងលើនេះ ជាបទល្មើសខាងសារពើពន្ធ ឬនយោបាយ ឬក៏ជាបទល្មើសដែលមានមូលហេតុនយោបាយ ដើម្បីប្រកែកមិនព្រមធ្វើបត្យាប័នចារីនៃបទល្មើសទាំងនោះ ឬមិនព្រមជួយ

គ្នាទៅវិញទៅមកក្នុងការស៊ើបអង្កេតការចោទប្រកាន់ពីបទអាជ្ញា និងនីតិវិធីនៃតុលាការចំពោះបទល្មើសខាងលើនេះឡើយ ។

## ផ្នែកទី ២
## បត្យាប័ន

### មាត្រា ១០២.-

ល័ក្ខខ័ណ្ឌ នីតិវិធីនិងលទ្ធផលនៃបត្យាប័នចំពោះបទល្មើស ដែលមានចែងជាពិសេសក្នុងជំពូកទី ១០ និងទី ១១ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃជំពូកទី២៥នៃច្បាប់នេះ ។

### មាត្រា ១០៣.-

បត្យាប័ននឹងត្រូវបានបដិសេធន៍ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា កាលបើអាជ្ញាធរខាងតុលាការកម្ពុជាយល់ថា បទល្មើសមិនធ្ងន់សមល្មមនឹងធ្វើបត្យាប័ន ឬកាលបើអាជ្ញាធរតុលាការកម្ពុជាយល់ថាវិធានការនេះ អាចសម្រួលឱ្យធ្វើការចោទប្រកាន់ឬដាក់ទ័ណ្ឌកម្មព្រហ្មទ័ណ្ឌទៅលើជនណាម្នាក់ដោយសារតែមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬមតិនយោបាយរបស់គេ ។

### មាត្រា ១០៤ .-

លើកលែងតែមានកិច្ចព្រមព្រៀង ឬការសម្រុះសម្រួលជាមួយនិងរដ្ឋដែលជាអ្នកប្តឹងសុំរាជរដ្ឋាភិបាលកម្ពុជា ដាក់រឿងជូនទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីចាត់ការជុំនុំជំរះបណ្តឹងព្រហ្មទ័ណ្ឌ កាលបើរាជរដ្ឋាភិបាលបដិសេធន៍បត្យាប័នដោយមូលហេតុ :

-បទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើនាវាបង្ហូតទង់ជាតិខ្មែរ ឬនៅលើអាកាសយានមានលេខសំគាល់ស្របទៅនឹងច្បាប់កម្ពុជាជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

-បទល្មើសត្រូវបានប្រព្រឹត្តដោយពលរដ្ឋខ្មែរ

-ឬអ្នកដែលសន្មត់ថាបានប្រព្រឹត្តបទល្មើសស្ថិតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ១០៥.-

កាលបើរាជរដ្ឋាភិបាលប្រកែកមិនព្រមធ្វើបត្យាប័ន ដែលគេសុំដើម្បីអនុវត្តទោសដែលត្រូវបានផ្តន្ទាទោសចំពោះបទល្មើសណាមួយដែលមានចែងក្នុងជំពូកទី ១០ និងទី ១១ ដោយសម្អាងថាទណ្ឌិតជាពលរដ្ឋខ្មែរ ហើយបើរដ្ឋជាអ្នកសុំនោះ សុំឱ្យរាជរដ្ឋាភិបាលកម្ពុជាចាត់ឱ្យអនុវត្តទោស ឬសំណល់ទោសដោយខ្លួនឯង នោះរាជរដ្ឋាភិបាលបញ្ជូនពាក្យសុំទៅក្រសួងយុត្តិធម៌ ដើម្បីពិនិត្យពីនិយតភាពនៃបណ្តឹង និងពីភាពត្រឹមត្រូវតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចសម្រេចទៅតាមច្បាប់ ។ កាលបើទោសដែលបានផ្តន្ទាតាមប្រភេទឬតាមចិរវេលា ជាទោសមានភាពធ្ងន់ជាងទោសដែលចែងក្នុងច្បាប់កម្ពុជាចំពោះរឿងដូចគ្នា នោះតុលាការនៃលំនៅដ្ឋាន ឬនៅទីឃុំឃាំងទណ្ឌិត តាមបណ្តឹងដែលធ្វើឡើងដោយទណ្ឌិតខ្លួនឯង ឬដោយអយ្យការ ត្រូវយកទោសដែលស្របនឹងច្បាប់កម្ពុជាមកដាក់ជំនួស ឬបន្ថយទោសដែលកាត់នៅឯបរទេសមកត្រឹមទោសអតិបរមាដែលមានចែងក្នុងច្បាប់កម្ពុជា ។

## មាត្រា ១០៦.-

បើកាលៈទេសៈទាមទារ ហើយក្នុងករណីប្រញាប់ ព្រះរាជអាជ្ញាអាចបញ្ជាឱ្យចាប់ខ្លួនជនបរទេសជាបណ្តោះអាសន្ន បន្ទាប់ពីបានទទួលដំណឹងដែលបានធ្វើផ្ទាល់មកខ្លួន តាមគ្រប់មធ្យោបាយបញ្ជូនសារ ដែលមានទុកស្នាមជាលាយល័ក្ខអក្សរថា នៅរដ្ឋជាអ្នកសុំមានសេចក្តីសម្រេចពីតុលាការបញ្ជាឱ្យចាប់ខ្លួនឬដាក់ទោសសាមីខ្លួននោះ ពីការប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងជំពូកទី ១០ និងទី ១១ ។ ព្រះរាជអាជ្ញាជូនដំណឹងអំពីការចាប់ខ្លួននេះទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ជនដែលត្រូវចាប់ខ្លួនជាបណ្តោះអាសន្នក្នុងល័ក្ខខ័ណ្ឌខាងលើនេះ អាចត្រូវបានដោះលែងឱ្យរួចខ្លួនវិញ បើក្នុងរយៈពេល ២០ថ្ងៃ ចាប់ពីថ្ងៃចាប់ខ្លួនមក រាជរដ្ឋាភិបាលកម្ពុជា ឥតបានទទួលពាក្យសុំបត្យាប័នជាផ្លូវការទេ ។

**មាត្រា ១០៧.-**

រាជរដ្ឋាភិបាលកម្ពុជាអាចយល់ព្រមឱ្យធ្វើបត្យាប័ន ដោយគ្រាន់តែបានឃើញពាក្យសុំចាប់ខ្លួនបណ្តោះអាសន្នបើជនដែលគេទាមទារឱ្យចាប់ខ្លួននោះយល់ព្រមជាលាយល័ក្ខអក្សរ នៅចំពោះមុខព្រះរាជអាជ្ញា ឱ្យគេបញ្ជូនខ្លួនត្រឡប់ទៅប្រទេសដើមវិញភ្លាម ។

## ផ្នែកទី ៣

## ការជួយគ្នាទៅវិញទៅមកខាងតុលាការ

**មាត្រា ១០៨.-**

ក្នុងករណីនៃបទល្មើសដែលមានចែងក្នុងជំពូកទី ១០ និងទី ១១ អាជ្ញាធរខាងតុលាការនៃព្រះរាជាណាចក្រកម្ពុជា អាចប្រគល់អំណាចឱ្យទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចនៃរដ្ឋបរទេសណាមួយនិងអាចទទួលអំណាចពីអាជ្ញាធរតុលាការនៃរដ្ឋបរទេសណាមួយដែរ ដើម្បី :

១-ប្រមូលយកសក្ខីភាពឬយកចម្លើយដែលឆ្លើយតាមផ្លូវតុលាការ ។

២-ឱ្យដំណឹងពីលិខិតផ្សេងៗ របស់តុលាការ ។

៣-ធ្វើការឆែកឆេរនិងឃាត់ទុក ។

៤-ធ្វើការពិនិត្យវត្ថុ និងទីកន្លែង ។

៥-ផ្តល់ពត៌មាននិងវត្ថុតាង ។

៦-ចេញច្បាប់ដើម ឬសេចក្តីចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃឯកសារ និងសំណុំរឿងរាប់ទាំងសេចក្តីស្រង់បញ្ជីប្រាក់ពីធនាគារ ឯកសារគណនេយ្យ សំណុំរឿងរបស់ក្រុមហ៊ុននិងឯកសារពាណិជ្ជកម្ម ព្រមទាំងលិខិតយថាភូត ឬលិខិតឯកជន ។

៧-បង្ហាញឬផ្តល់សាក្សី អ្នកជំនាញឬជនដទៃទៀត រាប់ទាំងជនជាប់ឃុំខ្លួនផង ដែលយល់ព្រមជួយក្នុងការស៊ើបអង្កេតឬយល់ព្រមចូលរួមក្នុងនីតិវិធី ។

៨-ផ្ទេរនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលការផ្ទេរនេះត្រូវធ្វើជាចាំបាច់ ក្នុងផលប្រយោជន៍គ្រប់គ្រងការងារតុលាការឱ្យបានល្អ ។

៩-រកអត្តសញ្ញាណ ឬរាវរកធនធាន ទ្រព្យសម្បត្តិ បរិក្ខារ សម្ភារៈ និងសារធាតុទាំងឡាយដើម្បីប្រមូលធាតុផ្សំនៃភស្តុតាង ។

១០-ដាក់ក្រោមវិធានការរក្សាទុកជាបណ្តោះអាសន្ននូវផលិតផលនិងទ្រព្យសម្បត្តិ ដែលបានមកពីបទល្មើស ព្រមទាំងបរិក្ខារ សម្ភារៈនិងសារធាតុដែលប្រើប្រាស់ឬទុកសម្រាប់ប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ។

១១-ចាត់ឱ្យអនុវត្តសេចក្តីសម្រេច ដែលបញ្ជាឱ្យធ្វើការរឹបអូសផលិតផល ទ្រព្យសម្បត្តិ បរិក្ខារ សម្ភារៈ និងសារធាតុទាំងឡាយ ។

១២-បញ្ជាឱ្យធ្វើការរឹបអូសវត្ថុទាំងឡាយ ដែលមានចែងក្នុងចំណុចខាងលើ ។

១៣-ឱ្យដំណឹងអំពីការចោទប្រកាន់ ក្នុងនីតិវិធីព្រហ្មទណ្ឌ ។

១៤-សួរចម្លើយជនជាប់ចោទ ក្នុងនីតិវិធីព្រហ្មទណ្ឌ ។

ល័ក្ខខ័ណ្ឌទាំងឡាយនៃការសុំជំនួយខាងតុលាការទៅបណ្តារដ្ឋបរទេស ឬល័ក្ខខ័ណ្ឌដែលត្រូវចាត់ការលើពាក្យសុំជំនួយខាងតុលាការពីបណ្តារដ្ឋបរទេស ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ២៦

# ការសម្របសម្រួលការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ និងការធ្វើជំនួញគ្រឿងញៀនខុសច្បាប់

## ផ្នែកទី ១

### ការសម្របសម្រួល ការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់

### គ្រឿងញៀនដោយបំពាន

**មាត្រា ១០៩.-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុវត្តនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ដោយបំពាននូវគ្រឿងញៀន ។

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិ រៀបចំការប្រជុំពិភាក្សារបស់អាជ្ញាធរជាតិ និងដាក់ចុះឱ្យអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់អាជ្ញាធរជាតិ ។

សមាសភាព និងមុខនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

## ផ្នែកទី ២
## ការសម្របសម្រួលនៃការប្រយុទ្ធប្រឆាំងនឹងការធ្វើជំនួញគ្រឿងញៀនខុសច្បាប់

**មាត្រា ១១០.-**

នាយកមន្ទីរប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ ប្រមូលផ្តុំពត៌មានទាំងអស់ដែលអាចសម្រួលការស្រាវជ្រាវរកនិងការបង្ការជំនួញគ្រឿងញៀនខុសច្បាប់ ហើយសម្រួលប្រតិបត្តិការទាំងអស់នៅក្នុងផ្ទៃប្រទេស ក៏ដូចជាក្នុងផ្ទៃអន្តរជាតិ ដើម្បីបង្រ្កាបជំនួញគ្រឿងញៀនខុសច្បាប់ ។

សមាសភាព និងមុខនាទីរបស់នាយកមន្ទីរខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ២៧
# អវសានប្បញ្ញត្តិ

**មាត្រា ១១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

**ចែម ស្គួន**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
| **ព្រះហស្តលេខា :** | **ហត្ថលេខា :** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

លេខ ១២ ច.ល

ដើម្បីចម្លងចែក

ភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

**ណាឌី តាន់**